ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

( គជ.ខប )

សម្រាប់

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

អាណត្តិទី៥ ឆ្នាំ២០២២

(ថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២)

# មាតិកា


គោលបំណង ...... ១

**I. រចនាសម្ព័ន្ធ ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប ...... ២**

១. រចនាសម្ព័ន្ធ គធ.ខប ...... ២

២. សមាសភាព គធ.ខប និងលេខាធិការដ្ឋាននៃ គធ.ខប ...... ៣

៣. ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប ...... ៣

៤. ការសម្របសម្រួលការងារបញ្ចូល និងបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត ...... ៤

៥. មជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប ...... ៥

ក. ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ...... ៥

ខ. ទីតាំងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ...... ៥

គ. សន្តិសុខ និងសុវត្ថិភាពរបស់មជ្ឈមណ្ឌលក្នុងប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត តាមឃុំ សង្កាត់ ...... ៦

ឃ.ការគ្រប់គ្រងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ...... ៦

៦. ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ...... ៧

ក. សមាសភាពក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ...... ៧

ខ. ភារកិច្ចរបស់ក្រុមត្រួតពិនិត្យលទ្ធផល ...... ៨

គ. ករណីនីមួយៗសម្រាប់ក្រុមត្រួតពិនិត្យលទ្ធផលអនុវត្ត ...... ៨

៧.ក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ...... ៩

ក.ការទទួលខុសត្រូវ និងភារកិច្ចរបស់ក្រុមកំណត់ចំនួនអាសនៈ ...... ៩

ខ.ការអនុវត្តកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ និងការប្រើប្រាស់អ៊ីនធឺណិត ...... ១០

៨. ការប្រគល់ និងការទទួលកញ្ចប់ "គ ពិសេស" ស្បោង "គ" ដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ.ខប ...... ១០

ក. ការប្រគល់ ...... ១០

ខ. ការទទួល ...... ១០

**II. ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នៅ គធ.ខប ទាក់ទងនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់ ...... ១២**

១.អ្នកមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ ...... ១២

២.ពាក្យបណ្តឹង (ទ.១២០២) ...... ១២

ក.ព័ត៌មានចាំបាច់មួយចំនួនដែលត្រូវបំពេញក្នុង ទ.១២០២ ...... ១២

ខ.ពាក្យបណ្តឹងនៅ គធ.ខប ក្រោយរយៈពេលកំណត់ ...... ១៣

គ.ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ...... ១៣

ឃ.ពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែល គធ.ខប ទទួលបានក្នុងរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់.១៤
III. **កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់**..........១៤
១. ការណែនាំក្រុមត្រួតពិនិត្យលទ្ធផល..........១៤
២. ការកំណត់ និងការរៀបចំធ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍..........១៥
៣.សម្ភារ ឯកសារ និងគំរូប្លង់តុសម្រាប់ក្រុមត្រួតពិនិត្យលទ្ធផល..........១៦
IV. **ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គឃ.សប និង គធ.ខប**..........១៧
១.ដំណើរការនៃការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ន..........១៧
២.ការពិនិត្យសម្រេចរបស់ គធ.ខប នៅលើ ទ.១១១៦គព និងការប្រើប្រាស់..........១៩
៣.ការរៀបចំឯកសារឡើងវិញ..........១៩
V. **ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្ដឹង**..........២០
១.ករណីគ្មានភាពមិនប្រក្រតីធ្ងន់ធ្ងរ គធ.ខប មិនត្រូវបានអនុញ្ញាតឱ្យបើកកញ្ចប់សុវត្ថិភាព "ក"..........២០
២.ករណីមានភាពមិនប្រក្រតីធ្ងន់ធ្ងរ គធ.ខប ត្រូវបានអនុញ្ញាតឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនៃការិយាល័យបោះឆ្នោតមួយ ឬច្រើនក្នុងឃុំសង្កាត់ពាក់ព័ន្ធ..........២០
ក.នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព "ក"..........២០
ខ.របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ..........២១
គ.សំណុំឯកសារដែលត្រូវដាក់ជូន គធ.ខប ដើម្បីប្រជុំសម្រេច..........២២
ឃ.ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតឡើងវិញ..........២២
៣.ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់..........២៣
ក.ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់..........២៣
ខ.ករណី គធ.ខប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ..........២៥
៤.ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ ដែល គធ.ខប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្នសម្រាប់បញ្ជូនទៅ គ.ជ.ប..........២៦
ក.ការវេចខ្ចប់ សម្ភារ ឯកសារបោះឆ្នោត..........២៦

ខ.លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)....................................២៧

VI. **ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលមានសំឡេងលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គធ.ឃប** ....................................២៨

១.ការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ....................................២៨

២.ការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបេក្ខជនច្រើន.២៩

៣.ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ....................................៣០

VII. **ក្រុមកំណត់ចំនួនអាសនៈ**....................................៣១

១.សម្ភារ ឯកសារសម្រាប់ក្រុមកំណត់ចំនួនអាសនៈប្រើប្រាស់ ....................................៣១

២.ការងាររបស់ក្រុមកំណត់ចំនួនអាសនៈ....................................៣២

៣.ការបែងចែកអាសនៈ ....................................៣៣

ក. រូបមន្ត និងដំណើរការនៃការបែងចែកអាសនៈ....................................៣៣

ខ. ករណីក្នុងការអនុវត្តរូបមន្ត....................................៤០

គ. ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ឬច្រើនបោះបង់ចោលអាសនៈ ឬត្រូវបានលុបចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំសាយ....................................៤១

ឃ.ករណីអាសនៈនៅសល់ មានចំនួនតិចជាងចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលទ្ធផលមធ្យមភាគខ្ពស់បំផុតស្មើគ្នា គធ.ឃប ត្រូវអនុវត្តនីតិវិធីចាប់ឆ្នោតជាសាធារណៈ ....................................៤៧

៤. ការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ....................................៥០

៥. ការកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង..៥០

៦. ការបំពេញតារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ....................................៥៣

ក.តារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ....................................៥៣

ខ.ក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ.ឃប (ទ.១១០៨ធខ)......៥៣

គ.លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១)....................................៥៤

VIII. **ការវេចខ្ចប់ និងការបញ្ជូនលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងរាល់សម្ភារ ឯកសារបញ្ជូនទៅ គ.ជ.ប**........៥៤

១.ការវេចខ្ចប់សម្ភារ ឯកសារដែល គធ.ឃប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្ន ....................................៥៤

២.ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតដែល គធ.ឃប សម្រេចយល់ព្រមទទួលលទ្ធផលបណ្ដោះអាសន្ន ....................................៥៤

ក.សម្ភារ ឯកសារបោះឆ្នោតដាក់ក្នុងកញ្ចប់ "ឃ ពិសេស"....................................៥៤

ខ.សម្ភារ ឯកសារបោះឆ្នោតដាក់ក្នុងស្បោង "យ ពិនិត្យរួច"..................................................................................៥៥
គ.សម្ភារ ឯកសារបោះឆ្នោតដាក់ក្នុងស្បោង "យ មានបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក"" ....................................៥៦
ឃ.ការបញ្ជូន និងការប្រគល់ ទទួល..................................................................................................................៥៧
ង.ការវេចខ្ចប់សម្ភារ ឯកសារនៅសល់បញ្ជូនទៅ គ.ជ.ប.....................................................................................៥៧
XI.**ឧបសម្ព័ន្ធ** ...........................................................................................................................................៥៨
ឧបសម្ព័ន្ធ១..................................................................................................................................................៥៩
ឧបសម្ព័ន្ធ២ .................................................................................................................................................៦០
ឧបសម្ព័ន្ធ៣..................................................................................................................................................៦១
ឧបសម្ព័ន្ធ៤.................................................................................................................................................. ៦២
ឧបសម្ព័ន្ធ៥..................................................................................................................................................៦៤
ឧបសម្ព័ន្ធ៦..................................................................................................................................................៦៥
ឧបសម្ព័ន្ធ៧ .................................................................................................................................................៦៦
ឧបសម្ព័ន្ធ៨.................................................................................................................................................. ៦៧

# អក្សរកាត់

| | | |
|---|---|---|
| ១. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៣. | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៤. | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| ៥. | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៦. | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៧. | ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ៨. | ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |
| ៩. | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | ប.ន.ឃ.ស |
| ១០. | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១១. | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |
| ១២. | ទម្រង់បែបបទលេខ | ទ. |

# គោលបំណង

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នាថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២ ប្រព្រឹត្តទៅបានដោយរលូន តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គ.ជ.ប បានរៀបចំចងក្រងសៀវភៅណែនាំ គធ.ខប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នេះឡើង ដើម្បីលើកកម្ពស់ការយល់ដឹងដល់ គធ.ខប អំពីការទទួលខុសត្រូវលើភារកិច្ចដែលច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងសេចក្តីណែនាំផ្សេងៗរបស់ គ.ជ.ប តម្រូវឱ្យអនុវត្ត ជាពិសេសអំពី៖

- ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្រោមសមត្ថកិច្ចរបស់ខ្លួន
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងនៅគធ.ខប
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានពាក្យបណ្តឹងនៅគធ.ខប
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងមានពាក្យបណ្តឹងនៅ គធ.ខប
- ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតបញ្ជូនមក គ.ជ.ប ករណី គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់
- ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតបញ្ជូនមក គ.ជ.ប ករណី គធ.ខប សម្រេចព្យួរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់
- ការអនុវត្តកម្មវិធីបែងចែកអាសនៈដែលឈានដល់ការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់។

គធ.ខប និងភាគីពាក់ព័ន្ធត្រូវយកចិត្តទុកដាក់សិក្សាស្វែងយល់ និងអនុវត្តតាមសៀវភៅណែនាំនេះ ដើម្បីសម្រេចភារកិច្ចបានល្អ ត្រឹមត្រូវ ទាន់ពេលវេលា និងមានតម្លាភាព។

# គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

## I. រចនាសម្ព័ន្ធ ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប

គធ.ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលបង្កើតឡើងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន។

### ១. រចនាសម្ព័ន្ធរបស់ គធ.ខប




**១.លគធ.ខប**

| | |
|---|---|
| -ប្រធាន | ១រូប |
| -អនុប្រធាន | ១រូប |
| -សមាជិកយ៉ាងច្រើន | ៥រូប |

**២.អនុគណៈកម្មការបច្ចេកទេស**

-ប្រធាន លគធ.ខប ជាប្រធាន

-អនុប្រធាន លគធ.ខប ជាអនុប្រធាន

-សមាជិក គធ.ខប ជាប្រធានផ្នែកនីមួយៗ

-សមាជិក លគធ.ខប ជាអនុប្រធានផ្នែកនីមួយៗ

-អនុប្រធានផ្នែក លគធ.ខប ជាអនុប្រធាននៃផ្នែកនីមួយៗ

-អនុប្រធានផ្នែកនៃ គធ.ខប ទទួលបន្ទុកការងារភស្តុភាជាអនុប្រធានផ្នែក។

**៣.អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល**

-ប្រធាន គធ.ខប ជាប្រធាន

-អនុប្រធាន គធ.ខប ជាអនុប្រធាន

-ប្រធាន និងអនុប្រធាន លគធ.ខប ជាសមាជិក

**ភារកិច្ចប្រធាន លគធ.ខប**

ទទួលខុសត្រូវគ្រប់គ្រងការងារហិរញ្ញវត្ថុ អគារ រថយន្ត និងសម្ភារបរិក្ខារទាំងអស់របស់ គធ.ខប និងចុះហត្ថលេខាលើលិខិតស្នាមពាក់ព័ន្ធនឹងការងារទាំងអស់នេះ ហើយស្នើសុំយោបល់សម្រេចពីប្រធាន គធ.ខប។

**ភារកិច្ចប្រធានអនុគណៈកម្មការបច្ចេកទេស**

-ធានាថា សមាជិក សមាជិកានៃអនុគណៈកម្មការបច្ចេកទេសទាំងអស់ត្រូវបំពេញភារកិច្ចតាមផ្នែកនីមួយៗដែលខ្លួនទទួលខុសត្រូវ

-ចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ គធ.ខប

-ចុះហត្ថលេខាគ្រប់ឯកសារផ្លូវការរបស់អនុគណៈកម្មការបច្ចេកទេស។

## ២. សមាសភាព គធ.ខប និងលេខាធិការដ្ឋាននៃ គធ.ខប

គធ.ខប ត្រូវមានសមាសភាពចំនួន ៧រូប ដែលមានប្រធាន ១រូប អនុប្រធាន ១រូប និងសមាជិក ៥ រូប មានលេខាធិការដ្ឋានមួយជាជំនួយការ និងមានអនុគណៈកម្មការបច្ចេកទេស ដែលមានផ្នែកជំនាញចំនួន ៥ ដែលត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួនដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.យ.ស។

## ៣. ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប

គធ.ខប ត្រូវមានការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅឃុំ សង្កាត់ ក្នុងរាជធានី ខេត្តរបស់ខ្លួនតាមការប្រគល់សិទ្ធិអំណាច និងត្រួតពិនិត្យនីត្យានុកូលភាពដោយ គ.ជ.ប។ គធ.ខប ត្រូវ៖

- ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមរយៈការបោះឆ្នោតជាសម្ងាត់
- គោរព និងអនុវត្តផែនការមេ និងប្រតិទិននៃការបោះឆ្នោត គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសម្ភារ បរិក្ខារ សម្រាប់ការបោះឆ្នោត
- គោរព និងអនុវត្តច្បាប់ បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងគោលការណ៍ណែនាំរបស់ គ.ជ.ប និងក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត
- ចាត់វិធានការពាក់ព័ន្ធទៅនឹងកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងដំណើរការបោះឆ្នោត
- តាមដានត្រួតពិនិត្យការងារគ្រប់គ្រង និងប្រតិបត្តិការរបស់ គឃ.សប
- បែងចែកសម្ភារ បរិក្ខារបោះឆ្នោតជូន គឃ.សប
- ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត
- លើកគម្រោង និងអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីការបោះឆ្នោតក្នុងក្របខ័ណ្ឌរាជធានី ខេត្តដោយយោងតាមការណែនាំរបស់ គ.ជ.ប
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីដំណើរការបោះឆ្នោតដោយធ្វើការសម្របសម្រួលការងារអប់រំអ្នកបោះឆ្នោតនៅក្នុងក្របខ័ណ្ឌរាជធានី ខេត្តដោយសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាលនានា
- អនុវត្តការងារទាក់ទងនឹងបច្ចេកទេស ការអនុវត្តទំនើបកម្មបច្ចេកវិទ្យាព័ត៌មានក្នុងដំណើរការគ្រប់គ្រងការងាររដ្ឋបាល និងការបោះឆ្នោត
- សម្របសម្រួល និងត្រួតពិនិត្យការឃោសនាបោះឆ្នោតនៅក្នុងរាជធានី ខេត្ត
- ចាត់គ្រប់វិធានការ ដើម្បីធានាឱ្យមានភាពស្មើគ្នាក្នុងការប្រើប្រាស់អគារ ឬទីសាធារណៈដល់គណបក្សនយោបាយឈរឈ្មោះក្នុងអំឡុងពេលឃោសនាបោះឆ្នោត

- ដំណើរការកម្មវិធីផ្សព្វផ្សាយព័ត៌មាន
- លើកសំណើសុំ គ.ជ.ប តែងតាំងសមាសភាព គឃ.សប និង គ.ក.ប ក្នុងរាជធានី ខេត្ត និងធ្វើតារាងប្រាក់កម្រៃសម្រាប់សមាជិក និងមន្ត្រីនៃ គធ.ខប គឃ.សប និង គ.ក.ប តាមការណែនាំរបស់ គ.ជ.ប
- តាមដានការងារគ្រប់គ្រង និងចាត់ចែងរបស់ គឃ.សប ក្នុងការបូកសរុបលទ្ធផលបណ្ដោះអាសន្នពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន
- រៀបចំចាត់ចែងប្រមូល និងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន ប្រកាសលទ្ធផលបណ្ដោះអាសន្នតាមឃុំ សង្កាត់ កំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត
- រៀបចំវេចខ្ចប់ និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ព្រមទាំងសម្ភារបរិក្ខារ និងឯកសារបោះឆ្នោតពាក់ព័ន្ធក្នុងរាជធានី ខេត្តរបស់ខ្លួនជូនទៅ គ.ជ.ប
- ទទួលពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ និងដំណើរការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់
- ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចដែលបានណែនាំដោយ គ.ជ.ប
- ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត
- សហការចាត់ចែងការងារសន្តិសុខបោះឆ្នោតនៅក្នុងរាជធានី ខេត្ត
- ជូនយោបល់ដល់ គ.ជ.ប អំពីបរិយាកាសក្នុងរាជធានី ខេត្ត ដើម្បីចាត់វិធានការនានាធានាឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងមានតម្លាភាព
- វាយតម្លៃអំពីប្រសិទ្ធភាពការងាររបស់សមាជិកទាំងឡាយនៃ គឃ.សប
- អនុវត្តការងារដទៃទៀត ឬអនុវត្តសិទ្ធិអំណាចដទៃទៀត ដែលត្រូវបានប្រគល់ឱ្យដោយ គ.ជ.ប។

## ៤. ការសម្របសម្រួលការងារបញ្ចូល និងបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត

គធ.ខប មានភារកិច្ចផ្ដល់ការគាំទ្រដល់ គឃ.សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបឋមនៃការបោះឆ្នោតឱ្យបានទាន់ពេលវេលានៅល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត ដើម្បីបញ្ជូនទិន្នន័យតាមអ៊ីនធឺណិតមក គ.ជ.ប ធ្វើការផ្សព្វផ្សាយជូនដល់សាធារណជន និងភាគីពាក់ព័ន្ធ។ ក្នុងដំណើរការនេះ គធ.ខប ត្រូវតាមដានការបញ្ជូនរូបភាព និងទិន្នន័យកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយ គឃ.សប។ ប្រសិនបើពិនិត្យឃើញថា គឃ.សប មានការយឺតយ៉ាវ ឬមិនទាន់បានបញ្ជូន

ទិន្នន័យមក គ.ជ.ប ទេ គធ.ខប ត្រូវទំនាក់ទំនង និងណែនាំរំឭកដល់ គឃ.សប ពាក់ព័ន្ធឱ្យចាត់ចែងបញ្ជូនមក គ.ជ.ប ឱ្យទាន់ពេលពេលវេលា។

## ៥. មជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប

### ក. ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់៖

- ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់
- កំណត់ចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបាន
- ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- កំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតដែលត្រូវទទួលតំណែងជាប្រធាន កបឃ.ស ជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង តាមប្រមាណវិធីដោយដៃនិងតាមប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត កំណត់ដោយ គ.ជ.ប ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យ សម្រេចជាផ្លូវការ។

### ខ. ទីតាំងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

មជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប អាចមានទីតាំងនៅ លគធ.ខប ឬនៅអគារមួយផ្សេង ឬផ្នែកមួយផ្សេងដែលមានទំហំទូលាយល្មមអាចរៀបចំឱ្យមានកន្លែង ឬបន្ទប់បម្រុង ដូចខាងក្រោម៖

- កន្លែងទទួលកញ្ចប់ "គ ពិសេស" ស្បោង "គ" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ពីគ្រប់ឃុំ សង្កាត់ ចំណុះរាជធានី ខេត្តពាក់ព័ន្ធ ដែលត្រូវស្ថិតនៅក្បែរផ្លូវចូល
- បន្ទប់មួយធំទូលាយល្មមដែលអាចស្តុកកញ្ចប់ "គ ពិសេស" និងស្បោង "គ" ដាច់ដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ និងមានសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង
- បន្ទប់មួយដោយឡែកសម្រាប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដែល គឃ.សប បានប្រគល់ឱ្យ
- បន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន ដែលត្រូវមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើក្នុងពេលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ហើយដែលអាចទទួលបានទាំងក្រុមត្រួតពិនិត្យលទ្ធផលរបស់ គធ.ខប ទាំងភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្តឹងពាក់ព័ន្ធ ឬតំណាង
- បន្ទប់ស្អាតតូចមួយ (ប្រសិនបើមាន) សម្រាប់ដាក់គ្រឿងបរិក្ខារកុំព្យូទ័រ ដែលមានភ្ជាប់អ៊ីនធឺណិតមានទិន្នន័យគ្រប់គ្រាន់ពាក់ព័ន្ធនឹងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត និងមានបំពាក់កម្មវិធីប្រតិបត្តិការបែងចែកអាសនៈដែលរៀបចំ និងផ្តល់ជូនដោយ គ.ជ.ប។

### គ. សន្តិសុខ និងសុវត្ថិភាពរបស់មជ្ឈមណ្ឌលក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់

គធ.ឃបៈ

- ត្រូវបិទទ្វារ និងបង្អួចទាំងអស់នៃអគារមជ្ឈមណ្ឌលរបស់ គធ.ឃប ឱ្យបានត្រឹមត្រូវ
- ត្រូវចាត់មន្ត្រីម្នាក់ឱ្យទទួលបន្ទុកសណ្តាប់ធ្នាប់ក្នុងមជ្ឈមណ្ឌល
- ត្រូវចាត់មន្ត្រីម្នាក់ឱ្យប្រចាំការនៅមាត់ទ្វារចេញចូលដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន គធ.ឃប។ ទ្វារនោះត្រូវចាក់សោនៅពេលផុតម៉ោងធ្វើការ
- ត្រូវរៀបចំឱ្យមានបរិវេណសន្តិសុខមួយនៅអគារមជ្ឈមណ្ឌលនៃ គធ.ឃប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ដោយនៅខ្សែក្រវាត់ខាងក្រៅ ត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដើម្បីចាត់កម្លាំងការពារ និងទទួលបន្ទុកការពារ។ នៅខ្សែក្រវាត់ខាងក្នុងត្រូវចាត់កម្លាំងសន្តិសុខផ្ទាល់របស់ គធ.ឃប ដើម្បីការពារ។

### ឃ. ការគ្រប់គ្រងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

ជនគ្រប់រូបដែលមានវត្តមាននៅក្នុងបរិវេណសន្តិសុខ និងក្នុងមជ្ឈមណ្ឌលនៃ គធ.ឃប សម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គធ.ឃប។

- ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផល ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប
- ត្រូវបានអនុញ្ញាតឱ្យចូលក្នុងមជ្ឈមណ្ឌលនេះនូវជនទាំងឡាយដូចខាងក្រោមៈ
  - ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ឃប ដែលបានទទួលការតែងតាំង
  - ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្តឹងពាក់ព័ន្ធ ឬតំណាង
  - ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន ឬតំណាង គធ.ឃប មានសំណូមពរ ក្នុងករណីចាំបាច់
  - មន្ត្រី គ.ជ.ប ដែលកំពុងបំពេញភារកិច្ចស៊ើបអង្កេតអំពីបទល្មើសដែលគេបានចោទប្រកាន់ចំពោះសមាជិក ឬមន្ត្រី លគធ.ឃប ដែលចាត់ឱ្យជួយក្នុងដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់

- ត្រូវបានហាមឃាត់សកម្មភាពទាំងឡាយដូចខាងក្រោម នៅក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត៖
  - ការស្លៀកពាក់ ឬដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សណាមួយ
  - ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បំពេញចិត្ត ឬប្រឆាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ។

## ៦. ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប

គធ.ខប ត្រូវតែងតាំងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ចំនួនមួយ ឬច្រើនក្រុម ដោយយោងតាមចំនួនឃុំ សង្កាត់ ក្នុងរាជធានី ខេត្តនីមួយៗ។ ជាធម្មតា ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗអាចត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ចំនួន១០។

ចំពោះរាជធានី ខេត្តដែលមានចំនួនឃុំ សង្កាត់តិច ដូចជាខេត្តកែប ខេត្តប៉ៃលិន ខេត្តព្រះសីហនុ.....ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗអាចត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ចំនួនតិចជាង១០។

ចំពោះរាជធានី ខេត្តដែលមានចំនួនឃុំ សង្កាត់ច្រើន ដូចជារាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តតាកែវ...ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗអាចត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ចំនួនច្រើនជាង១០។

គធ.ខប អាចបែងចែកឱ្យក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗទទួលបន្ទុកឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌមួយ ឬលើសពីមួយ។

### ក. សមាសភាពក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប

សមាសភាពក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗត្រូវមាន ៤រូប៖

- ប្រធាន ១ រូប ដែលជាសមាជិក គធ.ខប ឬមន្ត្រី លគធ.ខប
- អនុប្រធាន ១ រូប
- លេខាធិការ ១ រូប
- ជំនួយការ ១ រូប

**ចំណាំ៖**

- គធ.ខប ត្រូវជ្រើសតាំងក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗពីក្នុងចំណោមសមាជិក គធ.ខប និងមន្ត្រីនៃ លគធ.ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីណាដែលពេលនោះមិនសូវមានការងារមមាញឹក ដូចជាគ្រូបង្ហាត់ជាដើម

- បើ គធ.ខប ពុំមានមន្ត្រី បុគ្គលិកគ្រប់គ្រាន់ គធ.ខប អាចលើកសំណើសុំតែងតាំងសមាជិកនៃ គឃ.សបដែលស្ថិតនៅជិត លគធ.ខប បញ្ចូលក្នុងក្រុមត្រួតពិនិត្យលទ្ធផលទាំងនោះ
- ក្រុមត្រួតពិនិត្យលទ្ធផលខាងលើ មានភារកិច្ចត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ តាមចំនួនឃុំ សង្កាត់ដែលក្រុមទទួលបន្ទុកប៉ុណ្ណោះ។

**ខ. ភារកិច្ចរបស់ក្រុមត្រួតពិនិត្យលទ្ធផល**

ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗរបស់ គធ.ខប មានភារកិច្ចត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗទៅតាមករណីដោយឡែកពីគ្នា និងតាមការណែនាំរបស់ប្រធាន គធ.ខប ដោយផ្អែកលើ៖

- កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ.១១០៣)
- តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ.១១០៤)
- ទិន្នន័យលទ្ធផលនៃការបោះឆ្នោតដែល គឃ.សប បានបញ្ជូនតាមអ៊ីនធឺណិត ឬហ្លាស់ (USB Drive) រក្សាទុកទិន្នន័យដែល គឃ.សប បញ្ជូនមក
- កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលមានក្នុងស្រោមសំបុត្រ ផ្ញើជូន គធ.ខប (ក្នុងករណីចាំបាច់)
- របាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមានការបើកកញ្ចប់សុវត្ថិភាព "ក")
- សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គឃ.សប យល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (ប្រសិនបើមាន)
- ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គធ.ខប (ប្រសិនបើមាន)
- របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប (ប្រសិនបើ គធ.ខប សម្រេចឱ្យធ្វើដូច្នេះ)។

**គ. ករណីនីមួយៗសម្រាប់ក្រុមត្រួតពិនិត្យលទ្ធផលអនុវត្ត**

ផ្អែកតាមការណែនាំរបស់ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់ និងតាមលំដាប់លំដោយនៃករណីជាក់ស្តែងនីមួយៗដូចខាងក្រោម៖

- ករណីទី១ ឃុំ សង្កាត់ណាដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅគឃ.សប និងនៅគធ.ខប។
- ករណីទី២ ឃុំ សង្កាត់ណាដែលៈ
  - មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប
  - មានកញ្ចប់សុវត្ថិភាព "ក" ត្រូវបានបើកនៅគឃ.សប ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងសន្លឹកឆ្នោត
  - គឃ.សប បានយល់ព្រម ឬបដិសេធលើពាក្យបណ្ដឹង
  - មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប។
- ករណីទី៣ ឃុំ សង្កាត់ណាដែលមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន និងក្នុងករណីនោះមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ត្រូវបានដាក់នៅគធ.ខប។

### ៧. ក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប

គធ.ខប ត្រូវប្រគល់ឱ្យសមាជិក គធ.ខប ដែលជាប្រធានផ្នែករដ្ឋបាលដឹកនាំផ្ទាល់ក្រុមកំណត់ចំនួនអាសនៈ ដែលមានមន្ត្រីផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស ១ (មួយ) រូប មន្ត្រីផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ១ (មួយ) រូប និងមន្ត្រីមួយចំនួនទៀតតាមការចាំបាច់ជាសមាជិក និងលេខាធិការ ១ (មួយ) រូប។ ក្នុងចំណោមសមាជិកក្រុមត្រូវតែមានអ្នកមានចំណេះដឹងផ្នែកកុំព្យូទ័រ និងការប្រើប្រាស់អ៊ីនធឺណិត។

#### ក. ការទទួលខុសត្រូវ និងតារកិច្ចរបស់ក្រុមកំណត់ចំនួនអាសនៈ

ផ្អែកតាមតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ដែល គធ.ខប បានឯកភាពរួច

ក្រុមកំណត់ចំនួនអាសនៈៈ

- ត្រូវបោះពុម្ពក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) និងបោះពុម្ពតារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត (ទ.១១១០)
- ត្រូវផ្ទៀងផ្ទាត់តួលេខលទ្ធផលក្នុង ទ.១១០៥ធខ នៃឃុំ សង្កាត់ទាំងអស់ជាមួយនឹង ទ.១១១០។

ផ្អែកតាម ទ.១១០៥ធខ និង ទ.១១១៦គព ដែលផ្ទៀងផ្ទាត់រួច

ក្រុមកំណត់ចំនួនអាសនៈ៖

- ត្រូវអនុវត្តកម្មវិធីកុំព្យូទ័រ និងគណនាតាមប្រមាណវិធីដើម្បី៖
  - កំណត់ចំនួនអាសនៈដែលគណបក្សនីមួយៗទទួលបាន
  - ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបឃ.ស
  - កំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតដែលត្រូវទទួលតំណែងជាប្រធាន កបឃ.ស និងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង
- បោះពុម្ពលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ដែលត្រូវចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប។

**ខ. ការអនុវត្តកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ និងការប្រើប្រាស់អ៊ីនធឺណិត**

គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ បរិក្ខារកុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀតដល់ គធ.ខប សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ការបែងចែកអាសនៈ ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត និងកំណត់ឈ្មោះបេក្ខជនដែលត្រូវទទួលតំណែងជាប្រធាន កបឃ.ស ជាមេឃុំ ចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង។

អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវផ្ដល់ការគាំទ្រដល់ គធ.ខប អំពីការអនុវត្តកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត និងការប្រើប្រាស់អ៊ីនធឺណិត។

**ចំណាំ៖**

- គធ.ខប ប្រើប្រាស់អ៊ីនធឺណិតសម្រាប់តែការបញ្ជូនសារ លិខិតស្នាម ព័ត៌មានបន្ទាន់ និងទិន្នន័យបច្ចេកទេសក្នុងការបោះឆ្នោតប៉ុណ្ណោះ
- គ.ជ.ប ត្រូវធានាឱ្យមានទិន្នន័យបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្តពាក់ព័ន្ធនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**៨. ការប្រគល់ និងការទទួលកញ្ចប់ "គ ពិសេស" ស្បោង "គ" និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ.ខប**

**ក. ការប្រគល់**

នៅពេលទៅដល់មជ្ឈមណ្ឌលរបស់ គធ.ខប ភ្លាម ប្រធាន គឃ.សប ត្រូវប្រគល់ទៅឱ្យមន្ត្រីទទួលបន្ទុកទទួលសម្ភារ ឯកសារនៃ គធ.ខប នូវ៖

- កញ្ចប់ "គ ពិសេស" និងស្បោង "គ"
- កញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់
- លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ពាក់ព័ន្ធ

**ខ. ការទទួល**

ដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដែលប្រធាន គឃ.សប បានប្រគល់ឱ្យ មន្ត្រីទទួលបន្ទុកទទួលសម្ភារ ឯកសារនៃ លគធ.ខប ត្រូវ៖

- ត្រួតពិនិត្យផ្ទៀងផ្ទាត់៖
  • រាល់ស្បោង "ខ" ដែលមានក្នុងស្បោង "គ" និងសម្ភារ ឯកសារបោះឆ្នោតក្នុងកញ្ចប់ "គ ពិសេស"
  • កញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់
  • ចុះហត្ថលេខាលើ ទ.១១០៧ ពាក់ព័ន្ធ ដោយបញ្ជាក់ថា បានទទួលគ្រប់ចំនួន (ប្រសិនបើឃើញថាត្រឹមត្រូវ)
  • កត់ត្រាមុខសម្ភារ ឯកសារ ដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួន និងត្រូវចារសម្គាល់ថា "ប្រគល់គ្រប់ចំនួន"
  • ចាត់ចែងប្រើប្រាស់ ទ.១១០៧ ដែលបានចុះហត្ថលេខារួច ដូចខាងក្រោម៖

ទ.១១០៧ ចំនួន ៣ច្បាប់
- ១ច្បាប់ ប្រគល់ជូនប្រធាន គឃ.សប
- ១ច្បាប់ ដកទុកជាឯកសារ
- ១ច្បាប់ ដាក់ទៅក្នុងហោប៉ៅកញ្ចប់ "គ ពិសេស" ឬ ស្បោង "គ" ពាក់ព័ន្ធ

- ចាត់ចែង និងណែនាំសហការីរបស់ខ្លួនដែលទទួលបន្ទុករក្សាស្តុកឱ្យ៖
  ▪ នាំយកកញ្ចប់ "គ ពិសេស" និងស្បោង "គ" ពិនិត្យរួច ស្បោង "គ" មានបណ្តឹង/បើកកញ្ចប់សុវត្ថិភាព "ក" នៃឃុំ សង្កាត់នីមួយៗទៅដាក់ដោយឡែកៗពីគ្នាតាមឃុំ សង្កាត់ និងសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗដើម្បីងាយស្រួលរក
  ▪ នាំយកកញ្ចប់ដាក់សម្ភារឯកសារបោះឆ្នោតដែលនៅសល់ទាំងអស់ពីគ្រប់ឃុំ សង្កាត់ ចំណុះរាជធានី ខេត្តទៅដាក់ក្នុងបន្ទប់មួយនៃមជ្ឈមណ្ឌលដែលបានត្រៀមទុកស្រាប់។
- រាយការណ៍ពីចំនួនកញ្ចប់ "គ ពិសេស" ស្បោង "គ" និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោត នៅសល់ដែលបានទទួលពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ហើយត្រូវបញ្ជាក់ឱ្យច្បាស់នូវឈ្មោះ លេខកូដឃុំ សង្កាត់ដែលមានស្បោង "គ" មួយ ឬច្រើនសរសេរសម្គាល់ថា "មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព"ក" ជូន គជ.ខប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលទៅតាមករណីជាក់ស្តែង។

**ចំណាំ៖**

- ចំពោះឃុំ សង្កាត់ណាដែលមានស្បោង "គ" មួយ ឬច្រើនសរសេរសម្គាល់ថា "មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព "ក" មន្ត្រីនៃ លគជ.ខប ទទួលបន្ទុកការទទួលសម្ភារ ឯកសារបោះឆ្នោត ត្រូវចារបញ្ជាក់បន្ថែមទៀតថា "មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព "ក" ហើយស្រង់កត់ត្រាឈ្មោះ លេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ហើយដែលមានកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើនត្រូវបានបើកនៅ គឃ.សប ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត

- មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារបោះឆ្នោត ត្រូវយកស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) តាមឃុំ សង្កាត់ ដើម្បីបញ្ជូនឱ្យប្រធាន គធ.ខប ចាត់ចែងបូកសរុបចំនួនអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន រួចបញ្ជូនមក គ.ជ.ប។

## II. ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នៅ គធ.ខប ទាក់ទងនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់

### ១. អ្នកមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់

ជនគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានភស្តុតាងច្បាស់លាស់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ក្នុងដំណើរការបោះឆ្នោតដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅ គធ.ខប អំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ពាក់ព័ន្ធ។

**រយៈពេលនៃការប្តឹង និងការដោះស្រាយពាក្យបណ្តឹង**

- អ្នកប្តឹងត្រូវយកពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ ច្បាប់ ដែលបានបំពេញរួចទៅដាក់នៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពី គឃ.សប បានបិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣)
- គធ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងទាំងនោះក្នុងរយៈពេលយ៉ាងយូរ ៥ ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

### ២. ពាក្យបណ្តឹង (ទ.១២០២)

អ្នកប្តឹង៖

- ត្រូវស្នើសុំ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹងចំនួន៣ច្បាប់ ពី គឃ.សប
- ត្រូវបំពេញ និងផ្តល់ព័ត៌មានចាំបាច់លើ ទ.១២០២ គ្រប់ច្បាប់ រួចចុះហត្ថលេខា ឬផ្តិតមេដៃ
- ត្រូវយក ទ.១២០២ ទៅដាក់នៅ គធ.ខប តាមរយៈពេលកំណត់ដូចខាងលើ។

**ចំណាំ៖** ក្នុងរយៈពេលកំណត់ បើ គធ.ខប មិនបានទទួលពាក្យបណ្តឹងណាមួយទេ ត្រូវចាត់ទុកថា គ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ឡើយ។

ក. ព័ត៌មានចាំបាច់មួយចំនួនដែលត្រូវបំពេញក្នុង ទ.១២០២

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង
- លក្ខណៈសម្គាល់នៃ គឃ.សប ឬ/និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី

- កម្មវត្ថុនៃពាក្យបណ្តឹង
- ប្រសិនបើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ឃ.ស ឬ ប្រការនៃ ប.ន.ឃ.ស ដែលត្រូវបានរំលោភ
- មនុស្សដែលពាក់ព័ន្ធក្នុងភាពមិនប្រក្រតីនេះ
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)
- សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ដែលមានវត្តមាន ក្នុងពេលហេតុការណ៍កើតឡើង (ប្រសិនបើមាន)។

### ខ. ពាក្យបណ្តឹងនៅ គធ.ខប ក្រោយរយៈពេលកំណត់

**ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ៖**

- ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុទទួលពាក្យបណ្តឹង
- ត្រូវចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប លើ ទ.១២០២ និងចុះកាលបរិច្ឆេទគ្រប់ច្បាប់

ទ.១២០២ ចំនួន ៣ច្បាប់
- ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ រក្សាទុកជាឯកសារ

- ត្រូវជម្រាបអ្នកប្តឹង ឬតំណាងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយរយៈពេលកំណត់ គធ.ខប មិនអាចទទួលយកមកដោះស្រាយបានទេ។

### គ. ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់

**ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ៖**

- ត្រូវឱ្យអ្នកប្តឹងបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសរយៈពេលនៃការដាក់ពាក្យបណ្តឹង
- ត្រូវកត់ត្រាក្នុងកំណត់ហេតុ
- ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ ក្នុងករណីអ្នកប្តឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតតាមពេលកំណត់
- ត្រូវចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប លើ ទ.១២០២ និងចុះកាលបរិច្ឆេទគ្រប់ច្បាប់

ទ.១២០២ ចំនួន ៣ច្បាប់
- ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ រក្សាទុកជាឯកសារ

### ឃ. ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែល គធ.ឌប ទទួលបានក្នុងរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់

**មន្ត្រីទទួលពាក្យបណ្តឹងៈ**

- ត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹងលើទ.១២០២ ទាំង ៣ច្បាប់

ទ.១២០២ ចំនួន ៣ច្បាប់
  - ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
  - ១ច្បាប់ ផ្ញើជូន គ.ជ.ប
  - ១ច្បាប់ រក្សាទុកជាឯកសារ

- ត្រូវជម្រាបអ្នកប្តឹង ឬតំណាងថា គធ.ឌប នឹងប្រជុំសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ
- ត្រូវរាយការណ៍អំពីករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ខាងលើនេះជូនប្រធាន គធ.ឌប ជាបន្ទាន់ ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្តឹងនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬអ្នកពាក់ព័ន្ធ។

**ចំណាំៈ**

- ប្រសិនបើចាំបាច់ គធ.ឌប ត្រូវបង្គាប់ឱ្យក្រុមត្រួតពិនិត្យលទ្ធផលឱ្យបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យបោះឆ្នោតដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

## III. កិច្ចប្រតិបត្តិការរបស់ គធ.ឌប ក្នុងការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់

បន្ទាប់ពីបានទទួលកញ្ចប់ "គ ពិសេស" ស្បោង "គ" នៃឃុំ សង្កាត់មួយចំនួនហើយ គធ.ឌប ត្រូវចាត់វិធានការជាបណ្តើរៗឱ្យក្រុមត្រួតពិនិត្យលទ្ធផលធ្វើការពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតឃុំ សង្កាត់ដែលខ្លួនទទួលបន្ទុក តាមករណីនីមួយៗដោយឡែកពីគ្នា ទាំងឃុំ សង្កាត់ គ្មានពាក្យបណ្តឹង ទាំងឃុំ សង្កាត់ មានពាក្យបណ្តឹងឱ្យរួចរាល់ ឆាប់រហ័សតាមដែលអាចធ្វើបាន និងមិនត្រូវឱ្យហួសរយៈពេល ៥ថ្ងៃឡើយ ដោយគិតចាប់ពីថ្ងៃបានទទួលកញ្ចប់ "គ ពិសេស" និងស្បោង "គ" នៃឃុំ សង្កាត់ពាក់ព័ន្ធ។

### ១. ការណែនាំក្រុមត្រួតពិនិត្យលទ្ធផល

- គធ.ឌប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យអនុវត្តការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ដោយឡែកពីគ្នា និងតាមលំដាប់លំដោយនៃករណីជាក់ស្តែង ដូចខាងក្រោមៈ

- ករណីឃុំ សង្កាត់ណាដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប និង គជ.ខប
- ករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដាក់នៅ គឃ.សប និងមានកញ្ចប់សុវត្ថិភាព "ក" ត្រូវបានបើក ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ហើយ គឃ.សប បានយល់ព្រម ឬបដិសេធលើពាក្យបណ្ដឹងនោះ និងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គជ.ខប
- ករណីឃុំ សង្កាត់ណាដែលលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន និងក្នុងករណីឃុំ សង្កាត់នោះមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គជ.ខប។

- កិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ជាពិសេសឃុំ សង្កាត់មានពាក្យបណ្ដឹងទាក់ទងនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលបើកកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ
- ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ចំនួនពីរ ឬច្រើនក្រុមអាចបំពេញការងារនៅតាមតុរៀងខ្លួន នៅក្នុងបន្ទប់តែមួយ ឬនៅតាមបន្ទប់ដោយឡែកពីគ្នា ដោយយោងតាមលទ្ធភាពជាក់ស្ដែងរបស់រាជធានី ខេត្ត
- ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗត្រូវរៀបចំគំរូប្លង់បន្ទប់ តាមលំនាំបន្ទប់ការិយាល័យរាប់សន្លឹកឆ្នោត
- ប្រសិនបើលក្ខខណ្ឌតម្រូវ ក្រុមត្រួតពិនិត្យអាចធ្វើការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ពាក់ព័ន្ធ ដោយគួបផ្សំការអនុវត្តនីតិវិធី សម្រាប់ករណីលើសពីមួយ ស្របពេលជាមួយគ្នា។

**២. ការកំណត់ និងការរៀបចំភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍**

ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្ដឹង ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ចំណុះរាជធានី ខេត្តនៅមជ្ឈមណ្ឌលត្រួតពិនិត្យនៃ គជ.ខប។

- ភ្នាក់ងារគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនីមួយៗ ប្រចាំការតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យមានតំណាងពេញសិទ្ធិ និងតំណាងបម្រុងរបស់ខ្លួនតាមចំនួនដែល គជ.ខប បាន

កំណត់ដែលអាចចូលរួមគ្រប់គ្រាន់ល្មមក្នុងការសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គឃ.ឧប ព្រមទាំងអ្នកសារព័ត៌មានផងដែរ

- ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលត្រូវចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គឃ.ឧប នីមួយៗ អាចផ្លាស់ប្តូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួនបាន
- ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ និងអ្នកប្តឹងត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត
- ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាងអាចថតយករូបភាពនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តបាន ប៉ុន្តែមិនត្រូវបង្កការអុកឡុក ឬរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

**ចំណាំះ**

ក្នុងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹង និងមានកញ្ចប់សុវត្ថិភាព "ក" ត្រូវបានបើកដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ហើយ គឃ.សប សម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងនោះ និងក្នុងករណីឃុំ សង្កាត់ណាមានពាក្យបណ្តឹងត្រូវបានដាក់នៅ គឃ.ឧប ក្នុងរយៈពេលកំណត់ និងមានភស្តុតាងគ្រប់គ្រាន់ ហើយ គឃ.ឧប តម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតនោះឡើងវិញនោះ គឃ.ឧប ត្រូវអនុញ្ញាតឱ្យអ្នកប្តឹងនោះ ឬតំណាងពាក់ព័ន្ធនឹងពាក្យបណ្តឹងចូលរួមសង្កេតមើល ក្នុងការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធនោះ។

### ៣. សម្ភារ ឯកសារ និងគំរូប្លង់តុសម្រាប់ក្រុមត្រួតពិនិត្យលទ្ធផល

ក្រុមត្រួតពិនិត្យលទ្ធផលត្រូវមានសម្ភារ ឯកសារ និងទម្រង់បែបបទគ្រប់គ្រាន់សម្រាប់បំពេញការងារ។

- ក្នុងការត្រួតពិនិត្យលទ្ធផលនេះ ប្រធានក្រុមត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខប្រធានក្រុម ហើយឱ្យអនុប្រធានក្រុម និងជំនួយការអង្គុយនៅអមសងខាងតុទល់មុខគ្នា
- ប្រធានក្រុមត្រូវត្រៀមនៅក្បែរខ្លួនគាត់នូវពាក្យបណ្តឹង (ទ.១២០២) សម្រាប់ប្រគល់ជូនភ្នាក់ងារគណបក្សនយោបាយ ឬអ្នកប្តឹងដើម្បីបំពេញពាក្យបណ្តឹង ប្រសិនបើមាន

ការស្នើសុំ និងរាល់ទម្រង់បែបបទចាំបាច់ផ្សេងទៀត សម្រាប់ប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ

- ប្រធានក្រុមត្រូវប្រគល់ឱ្យអនុប្រធាន លេខាធិការនូវ ទ.១១១៦តព សម្រាប់ត្រួតពិនិត្យ
- ប្រធានក្រុមត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខ ១គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនេះ។




## IV. ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប និង គធ.ខប

ក្នុងករណីឃុំ សង្កាត់ណាដែល

- គ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គឃ.សប និងនៅ គធ.ខប និង
- មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប ប៉ុន្តែគ្មានកញ្ចប់សុវត្ថិភាព "ក" ណាមួយត្រូវបានបើក ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។

ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប

- មិនត្រូវបើកកញ្ចប់សុវត្ថិភាព "ក" ឡើយ
- គ្រាន់តែធ្វើការត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដោយផ្អែកលើ ទ.១១០៣ និង ទ.១១០៩ តែប៉ុណ្ណោះ ព្រមទាំងផ្ទៀងផ្ទាត់បន្ថែមជាមួយទិន្នន័យតួលេខលទ្ធផលដែលមានស្រាប់ក្នុងប្រព័ន្ធកុំព្យូទ័រ ឬនៅក្នុងហ្លាស់រក្សាទុកទិន្នន័យ (USB Drive)។

### ១. ដំណើរការនៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ន

គធ.ខប ត្រូវធានាថា ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងទាំងអស់ចំណុះរាជធានី ខេត្ត ត្រូវបានអនុវត្តម្តងមួយឃុំ សង្កាត់ៗជាបន្តបន្ទាប់ រហូតដល់អស់ឃុំ សង្កាត់គ្មានពាក្យបណ្តឹង និងតាមលំដាប់លំដោយ។

ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ឧប ត្រូវត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៃឃុំ សង្កាត់ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានរក្សាទុកក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោតឬនៅក្នុងហ្លាស់រក្សាទុកទិន្នន័យ (USB Drive) ធៀបនឹង ទ.១១០៣ និង ទ.១១០៩ ដែលទទួលបានពី គឃ.សប។ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ឧប ត្រូវចាត់ចែងអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

**ប្រធានក្រុមៈ**

- ត្រូវបង្គាប់ជំនួយការឱ្យនាំយកកញ្ចប់ "គ ពិសេស" នៃឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងម្តងមួយៗ ពីកន្លែងរក្សាស្តុកមកដាក់នៅលើតុចំពីមុខប្រធានក្រុម
- ត្រូវបើកកញ្ចប់ "គ ពិសេស" រួចដកយកស្រោមសំបុត្រដាក់ ទ.១១០៣ ទ.១១០៩ ស្រោមសំបុត្រដាក់ហ្លាស់រក្សាទុកទិន្នន័យ (USB Drive) លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងរាល់ស្រោមសំបុត្រដាក់ ទ.១១០១ ទ.១១០៨ ទ.១១០២ ដែលត្រូវផ្ញើជូន គធ.ឧប មកដាក់នៅលើតុ
- ត្រូវបញ្ជាប់ចូល (Login) ក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត ដើម្បីទាញយកទិន្នន័យពីសេវ្របករណ៍ (Server) គ.ជ.ប ឬហ្លាស់រក្សាទុកទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដើម្បីបង្ហាញលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឧបទស្សន៍កុំព្យូទ័រ (Monitor) ដើម្បីឱ្យភាគីពាក់ព័ន្ធដែលមានវត្តមានបានមើលឃើញទាំងអស់គ្នា
- ត្រូវចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ គណនាផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ក្នុងប្រព័ន្ធកុំព្យូទ័រធៀបនឹង ទ.១១០៣ និង ទ.១១០៩។

**ប្រធានក្រុមៈ**

- ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់បន្ថែមជាមួយ ទ.១១០១ ទ.១១០៨ ទ.១១០២ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ (បើមានភាពមិនច្បាស់លាស់)
- ត្រូវធានាថា ទ.១១១៦គព ២ច្បាប់ដែលបានបោះពុម្ពត្រូវបានផ្ទៀងផ្ទាត់បានត្រឹមត្រូវជាមួយគ្នា និងមានបញ្ជាក់ឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ
- ត្រូវធានាថា ទ.១១១៦គព ទាំង ២ច្បាប់ មានបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោមៈ
  - តួលេខលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់មានភាពត្រឹមត្រូវ
  - គឃ.សប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផល
  - បញ្ជីបេក្ខជននៃគណបក្សពីរ ឬច្រើនទទួលបានសន្លឹកឆ្នោតគាំទ្រស្មើគ្នាក្នុងការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ
  - ចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល
- ដាក់ក្នុងស្រោមសំបុត្រ ទ.១១១៦គព ទ.១១០៣ ទ.១១០៩ ជូនប្រធាន គធ.ឧប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដើម្បីពិនិត្យ និងសម្រេច។

ចំណាំ៖

បើ គឃ.សប មានកំហុសក្នុងការគណនាបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ប្រធានក្រុមត្រួតពិនិត្យត្រូវ៖

- បង្ហាញកំហុសនោះ និងការកែតម្រូវកំហុសនោះ ចំពោះមុខភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ដែលមានវត្តមាន
- ឆូតលើតួលេខដែលខុសតែមិនត្រូវធ្វើឱ្យបាត់លក្ខណៈសម្គាល់នៃតួលេខដើមនោះទេ រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង រួចស្កេនបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ និងកែតម្រូវតួលេខទាំងនោះក្នុងប្រព័ន្ធកុំព្យូទ័រផង
- ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិដាក់ពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ក្នុងករណីមិនពេញចិត្តនឹងការកែតម្រូវរបស់ប្រធានក្រុម។

## ២. ការពិនិត្យសម្រេចរបស់ គធ.ខប នៅលើ ទ.១១១៦តព និងការប្រើប្រាស់

ប្រសិនបើ គធ.ខប ពិនិត្យលើឯកសារដែលក្រុមត្រួតពិនិត្យលទ្ធផលបានប្រគល់ជូននោះឃើញថាមានភាពត្រឹមត្រូវ ប្រធាន គធ.ខប ត្រូវ៖

- ចារយល់ព្រមរួចចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើ ទ.១១១៦តព ទាំង២ច្បាប់
- ដាក់បង្ហាញ ទ.១១១៦តព ចំពោះមុខភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍។

ទ.១១១៦តព ចំនួន២ច្បាប់
- ១ច្បាប់ រួមនឹងទ.១១០៣ +ទ.១១០៩ ច្រកចូលក្នុងស្រោមសំបុត្រដើម ហើយជូនក្រុមត្រួតពិនិត្យលទ្ធផលដាក់ក្នុងកញ្ចប់ "គ ពិសេស" ដើម្បីទុកជាឯកសារនៅ គធ.ខប
- ១ច្បាប់ ជូនក្រុមកំណត់ចំនួនអាសនៈដើម្បីបន្តអនុវត្ត។

## ៣. ការរៀបចំឯកសារឡើងវិញ

ប្រធាន គធ.ខប ត្រូវធានាថា៖

- បានដាក់ ទ.១១០៣ ទ.១១០៩ ចូលក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្នងថា "កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ផ្ញើជូន គ.ជ.ប" ដើម្បីប្រមូលដាក់ក្នុងកញ្ចប់ "ឃ ពិសេស"
- បានដាក់ ទ.១១១៦តព ១ច្បាប់ និង ទ.១១០៣ ទ.១១០៩ នៃឃុំ សង្កាត់នីមួយៗ ចូលក្នុងស្រោមសំបុត្រដូចដើម ហើយប្រមូលដាក់ក្នុងកញ្ចប់ "គ ពិសេស" រួចយកទៅរក្សាទុកនៅកន្លែងស្តុកវិញ ដែលត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប។
- ទ.១១០១ ទ.១១០៨ ទ.១១០២ នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវបានច្រកចូលក្នុងស្រោមសំបុត្រដូចដើម ហើយប្រមូលដាក់ចូលក្នុងកញ្ចប់ "គ ពិសេស" និងរក្សាទុកជាឯកសារនៅ គធ.ខប។

## V.ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានពាក្យបណ្ដឹង

| | |
|---|---|
| ករណីឃុំ សង្កាត់ណាដែល | - មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប<br>- មានកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើនត្រូវបានបើកនៅ គឃ.សប ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត<br>- មានសម្រង់សេចក្ដីសម្រេចយល់ព្រម ឬបដិសេធរបស់ គឃ.សប លើពាក្យបណ្ដឹងនេះ<br>- មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដាក់នៅ គជ.ខប។ |

| | |
|---|---|
| ក្រុមត្រួតពិនិត្យលទ្ធផល៖ | - ត្រូវត្រួតពិនិត្យសម្រង់សេចក្ដីសម្រេចរបស់ គឃ.សប លើពាក្យបណ្ដឹងពាក់ព័ន្ធ<br>- ត្រូវពិនិត្យរបាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត<br>- ត្រូវពិនិត្យលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធដែលត្រូវបានដាក់នៅ គជ.ខប<br>- ត្រូវលើកយោបល់ស្នើទៅ គជ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដើម្បីសម្រេចអនុញ្ញាតឱ្យបើក ឬមិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។ |

**១. ករណីគ្មានភាពមិនប្រក្រតីធ្ងន់ធ្ងរ គជ.ខប មិនត្រូវបានអនុញ្ញាតឱ្យបើកកញ្ចប់សុវត្ថិភាព "ក"**

ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តតាមនីតិវិធីទាំងស្រុង ដូចករណីឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប និង គជ.ខប (មើល និងអនុវត្តទាំងស្រុងតាមIV)។

**២. ករណីមានភាពមិនប្រក្រតីធ្ងន់ធ្ងរ គជ.ខប ត្រូវអនុញ្ញាតឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនៃការិយាល័យបោះឆ្នោតមួយ ឬច្រើនក្នុងឃុំ សង្កាត់ពាក់ព័ន្ធ**

**ក. នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព "ក"**

| | |
|---|---|
| ជាដំបូងប្រធានក្រុមត្រួតពិនិត្យ៖ | ត្រូវត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃឃុំ សង្កាត់នោះដោយអនុវត្តដូចឃុំ សង្កាត់គ្មានពាក្យបណ្ដឹងដាក់នៅ គឃ.សប និងដាក់នៅ គជ.ខប (មើលនិងអនុវត្តតាមចំណុចលេខ១ នៃIV)។ |

| | |
|---|---|
| បន្ទាប់មកប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តដោយ៖ | - បង្គាប់ជំនួយការឱ្យនាំយកស្បោង "គ" មានបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក"នៃឃុំ សង្កាត់ពាក់ព័ន្ធ ពីបន្ទប់រក្សាស្ដុកមកដាក់នៅលើតុចំមុខប្រធាន<br>- បើកស្បោង "គ" នោះ ដកយកស្បោង "ខ" ចេញមកក្រៅ រួចបើក និងដកយកកញ្ចប់សុវត្ថិភាព "ក" មកដាក់នៅលើតុ។ |

បន្ទាប់មកប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តបន្ថែមដោយៈ

- បើកកញ្ចប់សុវត្ថិភាព "ក" រួចដកយកស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុងមកដាក់ដោយឡែកនៅលើតុ
- ប្រគល់ ទ.១១០១ ទ.១១០៨ ទ.១១០២ ឱ្យទៅលេខាធិការសម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាក្នុងកម្មវត្ថុនៃពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចខាងក្រោមៈ
  - ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
  - ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ
  - ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានមកបោះឆ្នោត
  - ពិនិត្យផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានទទួលពីការិយាល័យបោះឆ្នោតមកវិញ
  - រាប់ចំនួនសន្លឹកឆ្នោតខូច (ប្រសិនបើមាន)
  - រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ
  - ពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ
  - ពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ
- ពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការ តាមនីតិវិធីដូចដែលប្រធាន គ.ក.រ អនុវត្តនៅពេលរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតដែរ។

**ខ. របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ**

បន្ទាប់ពីបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យបោះឆ្នោតណាមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ រួចហើយប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងៈ

- ធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំនួន២ច្បាប់ដែលត្រូវៈ
  - ចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល
  - លើកយោបល់ស្នើសុំ គធ.ខប តាមរយៈប្រធានអនុគណកម្មការបច្ចេកទេសពិនិត្យសម្រេច

- គធ.ឃប សម្រេចយល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ/និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ
- គធ.ឃប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយត្រូវបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ
- ចារលើរបាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយបញ្ជាក់ខ្លឹមសារស្របនឹងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល។

**គ. សំណុំឯកសារដែលត្រូវដាក់ជូន គធ.ឃប ដើម្បីប្រជុំសម្រេច**

ប្រធានអនុគណៈកម្មការបច្ចេកទេស ត្រូវដាក់ជូន គធ.ឃបៈ
- របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលទាំង២ច្បាប់
- ទ.១១១៦តព ចំនួន២ច្បាប់ ទ.១១០៣ និង ទ.១១០៩
- សម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គឃ.សប លើពាក្យបណ្ដឹងពាក់ព័ន្ធ របាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" (បើមាន)។

**ឃ. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតឡើងវិញ**
- ដាក់សម្ភារ ឯកសារបោះឆ្នោត ទាំងអស់ទៅក្នុងស្បោងប្លាស្ទិក និងស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់ដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព "ក" តាមលំនាំដើមវិញ
- ដាក់កញ្ចប់សុវត្ថិភាព "ក" ទៅក្នុងស្បោង "ខ" រួចចងភ្ជិត
- ដាក់ស្បោង "ខ" ចូលទៅក្នុងស្បោង "គ" នៃឃុំ សង្កាត់ពាក់ព័ន្ធតាមលំនាំដើម ដែលត្រូវនាំយកទៅរក្សាទុកនៅកន្លែងដើមវិញ ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប។

**ចំណាំៈ**
- ចំពោះឃុំ សង្កាត់ណាដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដាក់នៅ គធ.ឃប ក្នុងរយៈពេលកំណត់ មានភស្តុតាងគ្រប់គ្រាន់ ប៉ុន្តែដាក់នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យរួចអស់ហើយ តាមករណីឃុំ សង្កាត់ដែលមានពាក្យបណ្ដឹងបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ គធ.ឃប ត្រូវប្រជុំសម្រេចដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យរួចហើយនោះ។
- ចំពោះឃុំ សង្កាត់ណាដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដាក់នៅ គធ.ឃប ក្នុងរយៈពេលកំណត់ មានភស្តុតាងគ្រប់គ្រាន់ ប៉ុន្តែដាក់នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យរួចអស់ហើយនៅឃុំ សង្កាត់ដែលមានពាក្យបណ្ដឹង

ពាក់ព័ន្ធនោះ ហើយ គធ.ខប បានអនុវត្តតាមនីតិវិធីត្រួតពិនិត្យដូចឃុំ សង្កាត់គ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប និងនៅ គធ.ខប មុននឹងប្រជុំសម្រេច គធ.ខប ត្រូវចាត់ក្រុមត្រួតពិនិត្យលទ្ធផលឱ្យបន្តអនុវត្តនីតិវិធីបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (មើល និងអនុវត្តតាមចំណុច២ នៃV)

- ចំពោះឃុំ សង្កាត់ណាដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដាក់នៅ គធ.ខប ក្នុងរយៈពេលកំណត់មានភស្តុតាងគ្រប់គ្រាន់ ហើយក្រុមត្រួតពិនិត្យលទ្ធផលមិនទាន់បានត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះនៅឡើយទេ ក្នុងករណីនេះមុននឹងប្រជុំសម្រេច គធ.ខប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យ៖
  - ត្រួតពិនិត្យដូចឃុំ សង្កាត់គ្មានពាក្យបណ្ដឹងតវ៉ាឬពាក្យបណ្ដឹងជំទាស់ដាក់នៅ គឃ.សប និងដាក់នៅ គធ.ខប (មើល និងអនុវត្តតាមចំណុច១ នៃ IV)
  - បន្តអនុវត្តនីតិវិធីបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (មើល និងអនុវត្តតាមចំណុច២ នៃV)។

### ៣. ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់

គធ.ខប ប្រជុំសម្រេច បន្ទាប់ពីក្រុមត្រួតពិនិត្យបានត្រួតពិនិត្យលទ្ធផលនៃឃុំ សង្កាត់មានពាក្យបណ្ដឹងរួចហើយ ដោយផ្អែកលើ៖

- របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារ និងរាប់សន្លឹកឆ្នោតឡើងវិញទាំង ២ច្បាប់ របស់ក្រុមត្រួតពិនិត្យលទ្ធផល
- សេចក្ដីសម្រេចរបស់ គឃ.សប លើពាក្យបណ្ដឹងពាក់ព័ន្ធ (ប្រសិនបើមាន)
- របាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារ និងសន្លឹកឆ្នោត (ប្រសិនបើមាន)
- ទ.១១១៦គត ចំនួន ២ច្បាប់ ទ.១១០៣ និង ទ.១១០៩
- ពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែល គធ.ខប បានទទួល។

#### ក. ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់

ប្រសិនបើ គធ.ខប យល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រធាន គធ.ខប ត្រូវ៖

- ចារយល់ព្រមលើ ទ.១១១៦គត ទាំង២ច្បាប់របស់ក្រុមត្រួតពិនិត្យលទ្ធផល
- ចារយល់ព្រមលើរបាយការណ៍ទាំង២ច្បាប់ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញរបស់ក្រុមត្រួតពិនិត្យលទ្ធផល

- ចារយល់ព្រមលើរបាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន)
- ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើឯកសារទាំង ៣ មុខខាងលើ រួចដាក់បង្ហាញភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាងដែលមានវត្តមាននៅក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផល
- ចារបដិសេធលើសម្រង់សេចក្តីសម្រេចរបស់ គឃ.សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធ (ប្រសិនបើមាន) រួចចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ
- ចាត់សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតឱ្យបំពេញ ទ.១២០៣ របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធដោយបញ្ជាក់ពីមូលហេតុ
- ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដោយសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត និងខ្លួនគាត់

ទ.១២០៣ចំនួនគ្រប់គ្រាន់:

- ១ច្បាប់ ប្រគល់ជូនអ្នកប្តឹង
- ១ច្បាប់ ជូនគ្រប់ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះ
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ
- ១ច្បាប់ ទុកជាឯកសារនៅ គធ.ខប

- ជម្រាបអ្នកប្តឹងថាគាត់មានសិទ្ធិប្តឹងទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៤ថ្ងៃ បន្ទាប់ពីបានទទួល ទ.១២០៣ របស់ គធ.ខប នេះ
- ជូន ទ.១២០២ ចំនួន៣ច្បាប់ (ប្រសិនបើគាត់ស្នើសុំ)
- ប្រគល់ឱ្យក្រុមត្រួតពិនិត្យលទ្ធផលដាក់ក្នុងកញ្ចប់ "គ ពិសេស" វិញដើម្បីរក្សាទុកជាឯកសារនៅ គធ.ខប នូវៈ
  - ទ.១១១៦តព ចំនួន១ ច្បាប់+របាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" របស់ក្រុមត្រួតពិនិត្យនៃ គធ.ខប ចំនួន១ច្បាប់+ទ.១១០៣ចំនួន១ច្បាប់+ទ១១០៩ចំនួន១ច្បាប់ និងច្បាប់ចម្លងរបាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" របស់ គឃ.សប
  - ទ.១២០៣ របស់ គឃ.សប ដែលត្រូវបានចារបដិសេធដោយ គធ.ខប ចំនួន១ច្បាប់ + ទ.១២០៣ របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ន ចំនួន ១ច្បាប់
- ប្រគល់ជូនក្រុមកំណត់ចំនួនអាសនៈដើម្បីបន្តអនុវត្តនូវ ទ.១១១៦តព ចំនួន ១ច្បាប់+របាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" របស់ គធ.ខប ចំនួន ១ច្បាប់+ របាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" របស់ គឃ.សប (ប្រសិនបើមាន)។

### ខ. ករណី គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ

ប្រសិនបើ គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ណាមួយ គធ.ខប ត្រូវយល់ព្រមតាមសេចក្តីសម្រេចរបស់ គឃ.សប និងត្រូវបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ហើយយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គធ.ខប ប្រធាន គធ.ខប ត្រូវ៖

- ចារព្យួរលទ្ធផលលើ ទ.១១១៦តព ទាំង២ច្បាប់
- ចារព្យួរលទ្ធផលលើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ទាំង ២ច្បាប់ របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប
- ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើឯកសារទាំង៣មុខខាងលើ ព្រមទាំងដាក់បង្ហាញចំពោះមុខអ្នកប្តឹង ឬតំណាង ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផល
- ចារយល់ព្រមលើ ទ.១២០៣ របស់ គឃ.សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធ រួចចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ
- ចាត់សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតឱ្យបំពេញ ទ.១២០៣ របស់ គធ.ខប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយបញ្ជាក់ពីមូលហេតុ
- ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដោយសមាជិក គធ.ខប ជាប្រធានផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត និងខ្លួនគាត់

ទ.១២០៣ ចំនួនគ្រប់គ្រាន់

- ១ច្បាប់ ប្រគល់ជូនអ្នកប្តឹង
- ១ច្បាប់ ជូនភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះនីមួយៗ
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ
- ១ច្បាប់ ទុកជាឯកសារនៅ គធ.ខប

- ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យណាមួយក្នុងឃុំ សង្កាត់នោះត្រូវបានបដិសេធដោយ គធ.ខប ហើយសេចក្តីសម្រេចនេះស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញរបស់ គ.ជ.ប
- ចាត់សមាជិក គធ.ខប ជាប្រធានផ្នែកសេវាកម្មច្បាប់និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតឱ្យដាក់ក្នុងស្រោមសំបុត្រដោយឡែកពីគ្នា ទុកផ្ញើជូន គ.ជ.ប នូវ៖
  - ទ.១២០៣ របស់ គធ.ខប ចំនួន១ច្បាប់ បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់

- របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ចំនួន១ច្បាប់+ ទ.១១១៦តព ចំនួន ១ច្បាប់ ដែលត្រូវបានចារព្យួរជាបណ្តោះអាសន្ន
- របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" របស់ គឃ.សប ចំនួន១ច្បាប់ (ប្រសិនបើមាន)

- ប្រគល់ឱ្យក្រុមត្រួតពិនិត្យលទ្ធផលដាក់កញ្ចប់ "គ ពិសេស" ដើម្បីទុកជាឯកសាររបស់ គធ.ខប នូវ៖
  - ទ.១២០៣ របស់ គឃ.សប ចំនួន ១ច្បាប់+ ទ.១១១៦តព ចំនួន១ច្បាប់+ទ.១១០៣ ចំនួន ១ច្បាប់+ទ.១១០៩ចំនួន ១ច្បាប់
  - របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" របស់ក្រុមត្រួតពិនិត្យលទ្ធផល ចំនួន ១ ច្បាប់ និងច្បាប់ចម្លងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" របស់ គឃ.សប
  - ទ.១២០២ ចំនួន១ច្បាប់ ទ.១២០៣ របស់ គធ.ខប ចំនួន ១ច្បាប់។

**ចំណាំ៖**

- ក្នុងករណី គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រធាន គធ.ខប ត្រូវបញ្ជូនសម្រង់សេចក្តីសម្រេចបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ និងសម្ភារ ឯកសារបោះឆ្នោត ពាក់ព័ន្ធមក គ.ជ.ប មិនឱ្យលើសពី២៤ម៉ោង គិតចាប់ពីពេលចេញសម្រង់សេចក្តីសម្រេច(ទ.១២០៣) ព្យួរលទ្ធផល។

**៨. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ដែល គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្នសម្រាប់បញ្ជូនទៅ គ.ជ.ប**

**ក. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោត**

ប្រធាន គធ.ខប ត្រូវធានាថា សម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធដែលត្រូវបានព្យួរលទ្ធផលត្រូវវេចខ្ចប់ដូចខាងក្រោម៖

❖ **ស្រោមសំបុត្រធំ**

ដាក់ក្នុងស្រោមសំបុត្រធំមួយនូវ៖

- ស្រោមសំបុត្រដាក់ ទ.១២០៣ របស់ គធ.ខប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតចំនួន ១ ច្បាប់
- ស្រោមសំបុត្រដាក់៖
  - របាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ចំនួន ១ ច្បាប់
  - តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ចំនួន ១ ច្បាប់
  - របាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" របស់ គឃ.សប (ប្រសិនបើមាន)

- ស្រោមសំបុត្រដាក់ ទ.១១០៣ ទ.១១០៩ នៃឃុំ សង្កាត់ ត្រូវព្យួរលទ្ធផលផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់ ទ.១១០៧ ចំនួន ១ច្បាប់

**ចំណាំ៖**

- ទ.១១០៧ ចំនួន ១ច្បាប់ កិបភ្ជាប់ខាងក្រៅស្រោមសំបុត្រធំ
- សរសេរសម្គាល់ពីលើស្រោមសំបុត្រធំថា៖
  - សេចក្តីសម្រេចព្យួរលទ្ធផលបណ្តោះអាសន្ន
  - លេខកូដឃុំ សង្កាត់....

❖ **ស្បោង "ឃ ព្យួរលទ្ធផល"**

ដាក់រាល់ស្បោង "គ" ផ្ទុកស្បោង "ខ" នៃឃុំ សង្កាត់ពាក់ព័ន្ធ ទៅក្នុងស្បោង "ឃ" ទៅតាមចំនួនដែលអាចដាក់បានឱ្យអស់ចំនួនស្បោង "គ" រួចចងភ្ជិតចាក់សោឃ្លុំ និងត្រូវសរសេរសម្គាល់ពីក្រៅស្បោង "ឃ" ថា "ព្យួរលទ្ធផលឃុំ សង្កាត់លេខ....."

**ខ. លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត** (ទ.១១០៧)

ប្រធាន គធ.ខប ចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន៣ច្បាប់ ដោយរាយមុខសម្ភារ ឯកសារដែលមានក្នុងស្រោមសំបុត្រធំ និងក្នុងស្បោង "ឃ ព្យួរលទ្ធផល"។

| | | |
|---|---|---|
| ទ.១១០៧ ចំនួន ៣ ច្បាប់ | - ១ច្បាប់ | ដាក់ក្នុងស្រោមសំបុត្រធំ |
| | - ១ច្បាប់ | កិបភ្ជាប់ផ្នែកខាងក្រៅនៃស្រោមសំបុត្រធំ |
| | - ១ច្បាប់ | សម្រាប់ប្រើក្នុងការប្រគល់ ទទួលនៅ គ.ជ.ប |

**ស្រោមសំបុត្រធំ**


លទ្ធផលសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត
នៅឃុំ សង្កាត់លេខ

- ស្រោមសំបុត្រដាក់ ទ.១២០៣ របស់ គធ.ខប បដិសេធលទ្ធផលនៃការបោះឆ្នោតចំនួន១ច្បាប់
- ស្រោមសំបុត្រដាក់៖
  - របាយការណ៍បើកកញ្ចប់សុវត្ថិភាព"ក"របស់ក្រុមត្រួតពិនិត្យលទ្ធផល គធ.ខប ចំនួន១ច្បាប់
  - តារាងត្រួតពិនិត្យលទ្ធផល(ទ.១១១៦គ៣)ចំនួន១ច្បាប់
  - របាយការណ៍បើកកញ្ចប់សុវត្ថិភាព"ក"របស់ គឃ.សប(ប្រសិនបើមាន)
  - ទ.១២០៣ របស់ គឃ.សប ដែលមានចំណាររបស់ គធ.ខប
- ស្រោមសំបុត្រដាក់ ទ.១១០៣ និង ទ.១១០៩ នៃឃុំ សង្កាត់ពាក់ព័ន្ធ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់ ទ.១១០៧ ចំនួន១ច្បាប់។

ទ.១១០៧ ចំនួន១ច្បាប់



## VI. ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន 0,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ.ខប

ក្នុងករណីឃុំ សង្កាត់ណាដែល៖ →

- មានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន 0,៥ ភាគរយ រវាងបញ្ជីបេក្ខជនគណបក្សពីរ ឬច្រើន និង
- មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅគធ.ខប។

↓

ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្តរូបមន្ត ដើម្បីរកកម្រិតលម្អៀងសំឡេងឆ្នោតតាមការសម្រេចរបស់ គធ.ខប។

### ១. ការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥តាគរយ រវាងបញ្ជីបេក្ខជនពីរ

ក្នុងការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ភាគរយ រវាងបញ្ជីបេក្ខជនពីរ ក្រុមត្រួតពិនិត្យលទ្ធផល ត្រូវ៖

- ស្រង់សំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងពីរដែលត្រូវបានយល់ថា អាចមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន០,៥ ភាគរយ

  **ឧទាហរណ៍ទី១៖**

  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក" មាន១.០០៥ សំឡេង
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ" មាន១.០០០ សំឡេង

- កំណត់យកសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលទាបជាងគេធ្វើជាភាគបែងសម្រាប់ប្រៀបធៀបរកភាគរយ។

  **ឧទាហរណ៍ទី២៖**

  ប្រៀបធៀបបញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក" ដែលមាន ១.០០៥ សំឡេង និងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ" ដែលមាន ១.០០០សំឡេង ដូចក្នុងឧទាហរណ៍ទី១ ក្រុមត្រួតពិនិត្យត្រូវកំណត់យកចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ" ដែលមានចំនួន ១.០០០ សំឡេងធ្វើជាភាគបែងសម្រាប់រកកម្រិតលម្អៀង។

- យកចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក" ដកនឹងចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ" គុណនឹង១០០ ចែកនឹងភាគបែង (ចំនួនសន្លឹកឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ") តាមរូបមន្ត៖

$$\text{ល}=\frac{(\text{ស}_{\text{ប}}\text{ក} - \text{ស}_{\text{ប}}\text{ខ})\times \text{១០០}}{\text{ស}_{\text{ប}}\text{ខ (ភាគបែង)}}$$

ល    តាងឱ្យចំនួននៃកម្រិតលម្អៀងរវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក" និង "ខ" (គិតជាភាគរយដល់ពីរខ្ទង់ក្រោយក្បៀស)

ស$_{ប}$ក    តាងឱ្យចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក"

ស$_{ប}$ខ    តាងឱ្យចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ" និងជាភាគបែង

**អនុវត្តរូបមន្តខាងលើចំពោះឧទាហរណ៍ទី១ យើងបាន៖**

$$ល=\frac{(១.០០៥ - ១.០០០)\times ១០០}{១.០០០}=០,៥$$

ដូចនេះ  កម្រិតលម្អៀងសំឡេងឆ្នោតរវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក" និង "ខ" គឺ "ល" ស្មើនឹង ០,៥ ភាគរយ។

**២. ការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនច្រើន**

ក្នុងការរកកម្រិតលម្អៀងសំឡេងឆ្នោត ដើម្បីកំណត់សំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ភាគរយ រវាងបញ្ជីបេក្ខជនច្រើន ក្រុមត្រួតពិនិត្យលទ្ធផលត្រូវ៖

- ជ្រើសយកបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរដែលមានចំនួនសំឡេងឆ្នោតខុសគ្នាតិចជាងគេ  ពីក្នុងចំណោមបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវបានយល់ថាអាចមានសំឡេងលម្អៀងរវាងគ្នានឹងគ្នាយ៉ាងច្រើន ០,៥ភាគរយ។

**ឧទាហរណ៍ទី៣៖**

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក" មាន១.០០៥ សំឡេង
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ" មាន១.០០០ សំឡេង
- បញ្ជីបេក្ខជននៃគណបក្សនយោបាយ "គ" មាន១.០០២ សំឡេង

ផ្អែកតាមសម្មតិកម្មក្នុងឧទាហរណ៍ទី៣ យើងឃើញថា៖

- រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក"  និងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ" មានសំឡេងឆ្នោតខុសគ្នា៥សំឡេង
- រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "ក"  និងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "គ" មានសំឡេងឆ្នោតខុសគ្នា៣សំឡេង
- រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "ខ"  និងបញ្ជីបេក្ខជននៃគណបក្សនយោបាយ "គ" មានសំឡេងឆ្នោតខុសគ្នា២សំឡេង

ដូចនេះក្រុមត្រួតពិនិត្យលទ្ធផលត្រូវកំណត់យកបញ្ជីបេក្ខជននៃគណបក្សនៃគណបក្សនយោបាយ"ខ" និង"គ" មានសំឡេងឆ្នោតខុសគ្នាតិចជាងគេ (២សំឡេង) មកគណនារកកម្រិតលម្អៀងសំឡេងឆ្នោតរវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងពីរ។

- ការគណនារកកម្រិតលម្អៀងសំឡេងឆ្នោត (ល) រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងពីរ ដែលមានសំឡេងខុសគ្នាតិចជាងគេ ក្នុងចំណោមបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលពាក់ព័ន្ធត្រូវអនុវត្តតាមរូបមន្តដូចខាងលើ។

**៣. ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានសំឡេងឆ្នោតសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន**

ក្នុងករណីឃុំ សង្កាត់ណាមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងក្នុងករណីឃុំ សង្កាត់នោះមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គជ.ខប គជ.ខប ត្រូវកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ដូចខាងក្រោម៖

ក. ប្រសិនបើឃុំ សង្កាត់ណាមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គជ.ខប ក្នុងរយៈពេលកំណត់ មានភស្តុតាងគ្រប់គ្រាន់ ប៉ុន្តែដាក់នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃឃុំ សង្កាត់នោះ តាមនីតិវិធីនៃការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃឃុំ សង្កាត់មានពាក្យបណ្ដឹងនៅ គឃ.សប មានបើកកញ្ចប់សុវត្ថិភាព "ក" នៅ គឃ.សប និងមានពាក្យបណ្ដឹងនៅ គជ.ខប ហើយមានការបើកកញ្ចប់សុវត្ថិភាព "ក" គជ.ខប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យរួចហើយនោះ ដើម្បីប្រជុំសម្រេចលើពាក្យបណ្ដឹង។

ខ. ប្រសិនបើឃុំ សង្កាត់ណាមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គជ.ខប ក្នុងរយៈពេលកំណត់ មានភស្តុតាងគ្រប់គ្រាន់ ប៉ុន្តែដាក់នៅក្រោយពេល ដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃឃុំ សង្កាត់នោះរួចអស់ហើយ ដោយអនុវត្តតាមករណីគ្មានពាក្យបណ្ដឹង មុននឹងប្រជុំសម្រេច គជ.ខប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យបន្តអនុវត្តបន្ថែមនីតិវិធីបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (មើល និង អនុវត្តតាមចំណុច២ ក្នុងV)។

គ. ប្រសិនបើឃុំ សង្កាត់ណាមានកម្រិតលម្អៀងគ្នាយ៉ាងច្រើន ០,៥ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន និងមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គជ.ខប ក្នុងរយៈពេលកំណត់ មានភស្តុតាងគ្រប់គ្រាន់ ហើយក្រុមត្រួតពិនិត្យលទ្ធផលមិនទាន់បានត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃឃុំ សង្កាត់នោះនៅឡើយ មុននឹងប្រជុំសម្រេច ប្រធាន គជ.ខប ត្រូវណែនាំក្រុមត្រួតពិនិត្យឱ្យ៖

- ត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃឃុំ សង្កាត់នោះដូចគ្នានឹងឃុំ សង្កាត់ គ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប និងនៅ គជ.ខប (មើល និងអនុវត្តតាមចំណុច១ ក្នុងចំណុចIV )

- បន្តអនុវត្តនីតិវិធីបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (មើល និង អនុវត្តតាមចំណុច២ ក្នុងV)។

បន្ទាប់មក គធ.ខប ត្រូវប្រជុំសម្រេចៈ

- ប្រសិនបើ គធ.ខប យល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ គធ.ខប ត្រូវអនុវត្តតាមចំណុច "ក" ត្រង់ចំណុច៣ ក្នុងចំណុច V
- ប្រសិនបើ គធ.ខប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ គធ.ខប ត្រូវអនុវត្តតាមចំណុច "ខ" ត្រង់ចំណុច៣ ក្នុងចំណុច V
- ការវេចខ្ចប់ និងការបញ្ជូនសម្ភារ ឯកសារបោះឆ្នោតនៅឃុំ សង្កាត់ ដែល គធ.ខប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្ន គធ.ខប ត្រូវអនុវត្តតាមចំណុច៤ ក្នុងចំណុច V។

**ចំណាំៈ**

ប្រសិនបើឃុំ សង្កាត់ណាមានសំឡេងលម្អៀងគ្នាយ៉ាងច្រើន០,៥ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ប៉ុន្តែឃុំ សង្កាត់នោះគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ទេនោះ គធ.ខប ត្រូវចាត់ចែងណែនាំក្រុមត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃឃុំ សង្កាត់នោះដូចគ្នានឹងឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ (មើល និងអនុវត្តតាមចំណុច១ ក្នុងចំណុច IV)។

## VII. ក្រុមកំណត់ចំនួនអាសនៈ

បន្ទាប់ពីបានទទួលតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦គ៣) និងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប និងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ គឃ.សប (ប្រសិនបើមាន) ដែល គធ.ខប បានចារយល់ព្រមទទួលយកលទ្ធផលរួចរាល់ហើយ ក្រុមកំណត់ចំនួនអាសនៈត្រូវបន្តអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួនដូចខាងក្រោមៈ

១. **សម្ភារ ឯកសារសម្រាប់ក្រុមកំណត់ចំនួនអាសនៈប្រើប្រាស់**

ប្រធាន គធ.ខបត្រូវៈ

- ធានាឱ្យមានកុំព្យូទ័រគ្រប់គ្រាន់ ដែលមានស្ដែនន័រ ម៉ាស៊ីនបោះពុម្ព អ៊ីនធឺណិត និងដែលបំពាក់ដោយកម្មវិធីប្រតិបត្តិការបែងចែកអាសនៈតាមរូបមន្ត និងនីតិវិធី
- ធានាថាគ្រឿងបរិក្ខារកុំព្យូទ័រត្រូវបានដំឡើង និងដំណើរការបានល្អត្រឹមត្រូវ ដោយមានផ្ទុកទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំសង្កាត់ទាំងអស់ក្នុងរាជធានី ខេត្តព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀត
- ធានាឱ្យមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ១ច្បាប់ សម្រាប់ក្រុមកំណត់ចំនួនអាសនៈប្រើប្រាស់ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់។

## សម្ភារ បរិក្ខារកុំព្យូទ័រសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២



## ២. ការងាររបស់ក្រុមកំណត់ចំនួនអាសនៈ:

ប្រធានក្រុមៈ

- ត្រូវត្រួតពិនិត្យសុពលភាព ទ.១១១៦តព និងរបាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" របស់ក្រុមត្រួតពិនិត្យលទ្ធផល ឬ/និងរបាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" របស់ គឃ.សប (ប្រសិនបើមាន) ដើម្បីឱ្យប្រាកដថា គជ.ខប បានចារយល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធរួចហើយ
- ត្រូវរៀបចំឯកសារដោយឡែក និងតាមលំដាប់លំដោយលេខកូដឃុំ សង្កាត់។

### - ផ្អែកតាមតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព)

ប្រធានក្រុមៈ

- ត្រូវឱ្យសមាជិកក្រុមផ្ទេរទិន្នន័យពី ទ.១១០៣ បញ្ចូលទៅក្នុង ទ.១១១០ តាមប្រព័ន្ធកុំព្យូទ័រ
- ត្រូវឱ្យសមាជិកក្រុមបោះពុម្ព ទ.១១០៥ធខ ចំនួន ៣ច្បាប់ ដោយពិនិត្យផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវតាម ទ.១១១៦តព របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប
- ត្រូវឱ្យលេខាធិការបោះពុម្ព ទ.១១១០ចំនួន ៣ច្បាប់
- ធានាថា ទ.១១០៥ធខ ទាំងអស់ដែលបានបោះពុម្ព ត្រូវបានផ្ទៀងផ្ទាត់ តួលេខលទ្ធផល ដោយធ្វើប្រមាណវិធីដោយដៃ ឬ/និងម៉ាស៊ីនគិតលេខ ហើយផ្ទៀបជាមួយនឹងតួលេខលទ្ធផលក្នុង ទ.១១១០ ដែលបានបោះពុម្ពពីកុំព្យូទ័រ។ ទ.១១១០ ចំនួន៣ច្បាប់ ទ.១១០៥ធខ ចំនួន៣ច្បាប់ ត្រូវចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ។

- **ផ្អែកតាម ទ.១១០៥ធខ និង ទ.១១១៦តព ដែលផ្ទៀងផ្ទាត់រួចៈ**

| ប្រធានក្រុម៖ | |
|---|---|
| ➡ | - ត្រូវអនុវត្តកម្មវិធីបែងចែកអាសនៈ និងបញ្ជាកម្មវិធីគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈ<br>- ត្រូវឱ្យលេខាធិការបោះពុម្ពលទ្ធផលនៃការកំណត់ចំនួនអាសនៈ ១ច្បាប់<br>- ត្រូវឱ្យសមាជិកដទៃទៀតក្នុងក្រុមអនុវត្តប្រមាណវិធីដោយដៃ ឬ/និងម៉ាស៊ីនគិតលេខដោយផ្អែកតាមរូបមន្តនៃការកំណត់ចំនួនអាសនៈ<br>- ត្រូវធ្វើការផ្ទៀងផ្ទាត់ឱ្យប្រាកដថាមានភាពត្រឹមត្រូវដូចគ្នា។ |

- ផ្អែកតាមការកំណត់ចំនួនអាសនៈខាងលើនេះ ប្រធានក្រុមត្រូវចាត់សមាជិកក្រុមឱ្យបោះពុម្ព ទ.១១១១ ចំនួន ៣ច្បាប់ ដោយផ្អែកលើបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយដែលបានទទួលអាសនៈតាមលំដាប់ពីខ្ពស់មកទាប ៖
  - ឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួនសំឡេងឆ្នោតគាំទ្រសរុបតាមគណបក្ស និងចំនួនអាសនៈដែលគណបក្សនីមួយៗទទួលបានដោយគិតតាមលំដាប់ពីខ្ពស់មកទាប
  - ឈ្មោះបេក្ខជននៃគណបក្សនយោបាយដែលត្រូវជាប់ឆ្នោតជាសមាជិក កបឃ.ស ក្នុងនោះត្រូវបញ្ជាក់ចំពោះបេក្ខជនដែលត្រូវជាប់ជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង។
- ប្រធានក្រុមត្រូវធានាថា ទ.១១១១ ចំនួន ៣ច្បាប់ ត្រូវបានចុះហត្ថលេខាសង្ខេបដោយសមាជិកក្រុមទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ។

## ៣. ការបែងចែកអាសនៈ

### ក. រូបមន្ត និងដំណើរការនៃការបែងចែកអាសនៈ

ដើម្បីបែងចែកអាសនៈក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ត្រូវអនុវត្តតាមករណីដូចខាងក្រោម៖

- ឃុំ សង្កាត់ណាដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតែមួយគត់ ឃុំ សង្កាត់នោះក៏ត្រូវធ្វើការបោះឆ្នោតដែរ ហើយឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះតាមលំដាប់លេខរៀងពីលើមកក្រោមរហូតដល់គ្រប់អាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នោះ
- ឃុំ សង្កាត់ណាដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយជាប់ឆ្នោតអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នោះត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតតាមជំហានដូចខាងក្រោម៖

▪ **ជំហានទី១ ការកំណត់កូតា**

កូតាគឺជាចំនួនសន្លឹកឆ្នោតបានការនៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗដែលកំណត់ឡើងសម្រាប់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះទទួលបាន១អាសនៈ។

- រូបមន្តដើម្បីកំណត់កូតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់មណ្ឌលបោះឆ្នោតឃុំ សង្កាត់នីមួយៗចែកនឹងចំនួនអាសនៈសរុបដែលបានកំណត់សម្រាប់ក្រុមប្រឹក្សានៃឃុំ សង្កាត់នីមួយៗ

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ

- $ក_{ត}$ តាងឱ្យកូតាដែលជាផលចែកមិនគិតសំណល់ចែក
- $ស_{ស}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប
- $អ_{ស}$ តាងឱ្យចំនួនអាសនៈសរុប

ឧទាហរណ៍

នៅមណ្ឌលបោះឆ្នោតនៃឃុំ A មានបញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៦ ឈរឈ្មោះបោះឆ្នោត៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** មានសន្លឹកឆ្នោតបានការ **ស**$_{ប}$**ក** = ១.១៧៩ សន្លឹក
- បញ្ជីបេក្ខជននៃគណបក្ស **ខ** មានសន្លឹកឆ្នោតបានការ **ស**$_{ប}$**ខ** = ២.២៧៥ សន្លឹក
- បញ្ជីបេក្ខជននៃគណបក្ស **គ** មានសន្លឹកឆ្នោតបានការ **ស**$_{ប}$**គ** = ៣.១៣១ សន្លឹក
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានសន្លឹកឆ្នោតបានការ **ស**$_{ប}$**ឃ** = ៣៨២ សន្លឹក
- បញ្ជីបេក្ខជននៃគណបក្ស **ង** មានសន្លឹកឆ្នោតបានការ **ស**$_{ប}$**ង** = ១.០៩១ សន្លឹក
- បញ្ជីបេក្ខជននៃគណបក្ស **ច** មានសន្លឹកឆ្នោតបានការ **ស**$_{ប}$**ច** = ២៩៤ សន្លឹក
- សន្លឹកឆ្នោតបានការ **ស**$_{ស}$ = ៨.៣៥២ សន្លឹក
- អាសនៈសរុប **អ**$_{ស}$= ១១អាសនៈ

អនុវត្តតាមរូបមន្តខាងលើយើងបាន៖

$$ក_{ត} = \frac{ស_{ស}}{អ_{ស}} = \frac{៨.៣៥២}{១១} = ៧៥៩$$

ដូចនេះកូតាស្មើនឹង ៧៥៩ ($ក_{ត}$=៧៥៩)

- **ជំហានទី២ ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈលើកទី១**

ដើម្បីកំណត់ចំនួនអាសនៈបឋមសម្រាប់ផ្តល់ឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ មកចែកនឹងកូតា តាមរូបមន្ត ដូចខាងក្រោម៖

$$អ_{ទូ} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ៖

**អ$_{ទូ}$** តាងឱ្យចំនួនអាសនៈ ជាផលចែកមិនគិតសំណល់ចែកដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២

**ស$_{ប}$** តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ

**ក$_{ត}$** តាងឱ្យកូតា

ឧទាហរណ៍

ការកំណត់ចំនួនអាសនៈបឋមនៅមណ្ឌល បោះឆ្នោតនៃឃុំ A ដដែល

អនុវត្តតាមរូបមន្ត ជំហានទី២ អាសនៈគណបក្សនីមួយៗទទួលបានលើកទី១៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** $អ_{ទូក} = \frac{១.១៧៩}{៧៥៩}$ =១,៥៥ ទទួលបាន **១អាសនៈ**
- បញ្ជីបេក្ខជននៃគណបក្ស **ខ** **$អ_{ទូខ}$** $= \frac{២.២៧៥}{៧៥៩}$ = ២,៩៩ ទទួលបាន **២អាសនៈ**
- បញ្ជីបេក្ខជននៃគណបក្ស **គ** **$អ_{ទូគ}$** $= \frac{៣.១៣១}{៧៥៩}$ =៤,១២ ទទួលបាន **៤អាសនៈ**
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** $អ_{ទូឃ} = \frac{៣៨២}{៧៥៩}$ =០,៥០ ទទួលបាន **០អាសនៈ**
- បញ្ជីបេក្ខជននៃគណបក្ស **ង** $អ_{ទូង} = \frac{១.០៨១}{៧៥៩}$ =១,៤៣ ទទួលបាន **១អាសនៈ**
- បញ្ជីបេក្ខជននៃគណបក្ស **ច** $អ_{ទូច} = \frac{២៩៤}{៧៥៩}$ =០,៣៨ ទទួលបាន **០អាសនៈ**

ចំណាំ៖

បន្ទាប់ពីគណនាតាមរូបមន្តជំហានទី២ គ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់រួចមក ហើយប្រសិនបើគ្មានអាសនៈនៅសល់នោះ ចំនួនអាសនៈត្រូវកំណត់យកតែម្តង។

- **ជំហានទី៣ ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈលើកទី២**

  - **គណនាមធ្យមភាគខ្ពស់របស់បញ្ជីបេក្ខជនគណបក្សនយោបាយនីមួយៗ**

    ដើម្បីគណនាមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ មកចែកនឹងចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលក្នុងការបែងចែកលើកទី១ បូកនឹងលេខនិមិត្តចំនួន១។

  - **រូបមន្ត** $ម_{ធ} \quad \frac{ស_{ប}}{អ_{ទ}+១}$ (គិតត្រឹមចំនួនពីរខ្ទង់ក្រោយក្បៀស)

    **$ម_{ធ}$** តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ

    **$ស_{ប}$** តាងឱ្យសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ

    **$អ_{ទ}$** តាងឱ្យចំនួនអាសនៈបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១

    **១** ជាលេខនិមិត្ត

  - ធ្វើការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដើម្បីឱ្យឃើញថា បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតទាំងចំនួនពីរខ្ទង់ក្រោយក្បៀស)
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុតត្រូវទទួលបានអាសនៈ១។

ឧទាហរណ៍

ការបែងចែកអាសនៈលើកទី២នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ A ដដែល។

បន្ទាប់ពីការបែងចែកអាសនៈលើកទី១ តាមរូបមន្ត ជំហានទី២ យើងបាន៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ: ១
- បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ: ២
- បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ: ៤
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ: ០
- បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ: ១

- បញ្ជីបេក្ខជននៃគណបក្ស **ច** បានទទួលអាសនៈ ០

យើងឃើញថា

- អាសនៈដែលបានបែងចែកលើកទី១ សរុបមាន ៨អាសនៈ
- អាសនៈសរុបនៃក្រុមប្រឹក្សាឃុំ មាន ១១អាសនៈ

ដូចនេះ អាសនៈនៅសល់ត្រូវបន្តបែងចែកលើកទី២មាន៣ អាសនៈទៀត។

អាសនៈ៣ដែលនៅសល់នេះ ត្រូវបន្តបែងចែកលើកទី២ ដោយអនុវត្ត តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

❖ គណនាមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ក} = \frac{១.១៧៩}{១+១} = ៥៨៩,៥០$
- បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ខ} = \frac{២.២៧៥}{២+១} = ៧៥៨,៣៣$
- បញ្ជីបេក្ខជននៃគណបក្ស **គ** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{គ} = \frac{៣.១៣១}{៤+១} = ៦២៦,២០$
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ឃ} = \frac{៣៨២}{០+១} = ៣៨២,០០$
- បញ្ជីបេក្ខជននៃគណបក្ស **ង** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ង} = \frac{១.០៩១}{១+១} = ៥៤៥,៥០$
- បញ្ជីបេក្ខជននៃគណបក្ស **ច** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ច} = \frac{២៩៤}{០+១} = ២៩៤,០០$

❖ ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សទាំង៦ ខាងលើឃើញថា គណបក្ស ខ មានមធ្យមភាគធំជាងគេគឺ ៧៥៨,៣៣ (មធ្យមភាគខ្ពស់បំផុត)។ ដូចនេះ គណបក្ស ខ ត្រូវទទួលបានអាសនៈ១ បន្ថែមទៀតនៅលើកទី២។

**ចំណាំ៖** ក្នុងករណីនៅមានសល់អាសនៈបន្ទាប់ពីការបែងចែកលើកទី២ ក្រុមកំណត់ចំនួនអាសនៈត្រូវបន្តបែងចែកអាសនៈនៅសល់នោះតាមរូបមន្តជំហានទី៣ ដដែលរហូតអស់អាសនៈនៅសល់នោះ។

**ឧទាហរណ៍**

ការបែងចែកលើកទី៣នៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ A ដដែល

បន្ទាប់ពីការបែងចែកអាសនៈលើកទី១ និងលើកទី២ យើងបាន៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ ១
- បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ ៣ (បាន**១អាសនៈ**បន្ថែមលើកទី២)
- បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ ៤
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ ០
- បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ ១
- បញ្ជីបេក្ខជននៃគណបក្ស **ច** បានទទួលអាសនៈ ០

យើងឃើញថាៈ

- ❖ អាសនៈដែលបានបែងចែកលើកទី១ និងទី២ សរុបមាន ៩អាសនៈ
- ❖ អាសនៈសរុបក្នុងក្រុមប្រឹក្សាឃុំ A មាន **១១អាសនៈ**

ដូចនេះ អាសនៈនៅសល់ត្រូវបន្តបែងចែកលើកទី៣ មាន២ អាសនៈ។

អាសនៈ២ដែលនៅសល់នេះ ត្រូវបន្តបែងចែកលើកទី៣តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ដដែល យើងបានៈ

- ❖ គណនាមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗៈ

- បញ្ជីបេក្ខជននៃគណបក្ស **ក** មានមធ្យមភាគ $ម_{ធ}ក = \frac{១.១៧៩}{១+១} = ៥៨៩,៥០$
- បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគ $ម_{ធ}ខ = \frac{២.២៧៥}{៣+១} = ៥៦៨,៧៥$
- បញ្ជីបេក្ខជននៃគណបក្ស **គ** មានមធ្យមភាគ $ម_{ធ}គ = \frac{៣.១៣១}{៤+១} = \boxed{៦២៦,២០}$
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគ $ម_{ធ}ឃ = \frac{៣៨២}{០+១} = ៣៨២,០០$
- បញ្ជីបេក្ខជននៃគណបក្ស **ង** មានមធ្យមភាគ $ម_{ធ}ង = \frac{១.០៩១}{១+១} = ៥៤៥,៥០$
- បញ្ជីបេក្ខជននៃគណបក្ស **ច** មានមធ្យមភាគ $ម_{ធ}ច = \frac{២៩៤}{០+១} = ២៩៤,០០$

- ❖ ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង៦ខាងលើ ឃើញថា គណបក្ស គ មានមធ្យមភាគធំជាងគេគឺ ៦២៦,២០ (មធ្យមភាគខ្ពស់បំផុត)
- ❖ ដូចនេះគណបក្ស គ ត្រូវទទួលបានអាសនៈ១បន្ថែមទៀតនៅលើកទី៣ គឺៈ

- បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ ១
- បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ៣ (បាន**១អាសនៈ**បន្ថែមលើកទី២)
- បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ ៥(បាន**១អាសនៈ**បន្ថែមលើកទី៣)
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ ០
- បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ ១
- បញ្ជីបេក្ខជននៃគណបក្ស **ច** បានទទួលអាសនៈ ០

យើងឃើញថា៖

❖ អាសនៈដែលបានបែងចែកលើកទី១ ទី២ និងទី៣ សរុបមាន ១០អាសនៈ

❖ អាសនៈសរុបក្នុងក្រុមប្រឹក្សាឃុំ A មាន **១១អាសនៈ**

ដូចនេះ អាសនៈនៅសល់១អាសនៈ ត្រូវបន្តបែងចែក។

អាសនៈ១ដែលនៅសល់នេះ ត្រូវបន្តបែងចែកលើកទី៤ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ដដែល យើងបាន៖

❖ គណនាមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ក} = \frac{\text{១.១៧៩}}{\text{១+១}} = \boxed{\text{៥៨៩,៥០}}$
- បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ខ} = \frac{\text{២.២៧៥}}{\text{៣+១}} = \text{៥៦៨,៧៥}$
- បញ្ជីបេក្ខជននៃគណបក្ស **គ** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{គ} = \frac{\text{៣.១៣១}}{\text{៥+១}} = \text{៥២១,៨៣}$
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ឃ} = \frac{\text{៣៨២}}{\text{០+១}} = \text{៣៨២,០០}$
- បញ្ជីបេក្ខជននៃគណបក្ស **ង** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ង} = \frac{\text{១.០៩១}}{\text{១+១}} = \text{៥៤៥,៥០}$
- បញ្ជីបេក្ខជននៃគណបក្ស **ច** មានមធ្យមភាគ $\text{ម}_{\text{ធ}}\text{ច} = \frac{\text{២៩៤}}{\text{០+១}} = \text{២៩៤,០០}$

❖ ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង៦ខាងលើ ឃើញថា គណបក្ស ក មានមធ្យមភាគធំជាងគេគឺ ៥៨៩,៥០ (មធ្យមភាគខ្ពស់បំផុត)

❖ ដូចនេះគណបក្ស ក ត្រូវទទួលបានអាសនៈ១បន្ថែមទៀតនៅលើកទី៤ ។

ជាសរុបបន្ទាប់ពីការគណនាតាមរូបមន្តជំហានទី១ ជំហានទី២ និងជំហានទី៣ លទ្ធផលនៃការបែងចែកអាសនៈក្នុងមណ្ឌលបោះឆ្នោតឃុំ A គឺ៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ ២

- បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ ៣
- បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ ៥
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ ០
- បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ ១
- បញ្ជីបេក្ខជននៃគណបក្ស **ច** បានទទួលអាសនៈ ០

**ខ. ករណីក្នុងការអនុវត្តរូបមន្តជំហានទី២ គ្មានគណបក្សណាមួយទទួលបានអាសនៈ**

ឧទាហរណ៍

ក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ B មាន៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ ៖ ចំនួន៧
- សន្លឹកឆ្នោតបានការសរុប ៖ $ស_{ស}$=៤.១០៨
- អាសនៈសរុប ៖ $អ_{ស}$=៥អាសនៈ
- កូតា ៖ $ក_{ត}$=៨២១

| បញ្ជីបេក្ខជននៃគណបក្ស | $ស_{ប}$ | $អ_{ទ១}$ | $ម_{ទ១}$ | $អ_{ទ២}$ | $ម_{ទ២}$ | $អ_{ទ៣}$ | $ម_{ទ៣}$ | $អ_{ទ៤}$ | $ម_{ទ៤}$ | $អ_{ទ៥}$ | $ម_{ទ៥}$ | $អ_{ទ៦}$ | លទ្ធផល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក | ៥៨២ | ០ | ៥៨២/(០+១) | ០ | ៥៨២/(០+១) | ០ | ៥៨២/(០+១) | ០ | ៥៨២/(០+១) | ១ | ៥៨២/(១+១) | ០ | ១ |
| ខ | ៧៥៤ | ០ | ៧៥៤/(០+១) | ១ | ៧៥៤/(១+១) | ០ | ៧៥៤/(១+១) | ០ | ៧៥៤/(១+១) | ០ | ៧៥៤/(១+១) | ០ | ១ |
| គ | ៣៨៣ | ០ | ៣៨៣/(០+១) | ០ | ៣៨៣/(០+១) | ០ | ៣៨៣/(០+១) | ០ | ៣៨៣/(០+១) | ០ | ៣៨៣/(០+១) | ០ | ០ |
| ឃ | ៦៣៧ | ០ | ៦៣៧/(០+១) | ០ | ៦៣៧/(០+១) | ០ | ៦៣៧/(០+១) | ១ | ៦៣៧/(១+១) | ០ | ៦៣៧/(១+១) | ០ | ១ |
| ង | ៥៦៤ | ០ | ៥៦៤/(០+១) | ០ | ៥៦៤/(០+១) | ០ | ៥៦៤/(០+១) | ០ | ៥៦៤/(០+១) | ០ | ៥៦៤/(០+១) | ១ | ១ |
| ច | ៤៦៧ | ០ | ៤៦៧/(០+១) | ០ | ៤៦៧/(០+១) | ០ | ៤៦៧/(០+១) | ០ | ៤៦៧/(០+១) | ០ | ៤៦៧/(០+១) | ០ | ០ |
| ឆ | ៧២១ | ០ | ៧២១/(០+១) | ០ | ៧២១/(០+១) | ១ | ៧២១/(១+១) | ០ | ៧២១/(១+១) | ០ | ៧២១/(១+១) | ០ | ១ |

$ស_{ប}$ តាងឱ្យសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ

$អ_{ទ១}$ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជនគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ជំហានទី២

មធ១ តាងឱ្យលទ្ធផលមធ្យមភាគលើកទី១ របស់បញ្ជីបេក្ខជនគណបក្សនយោបាយនីមួយៗ ហើយ បញ្ជីបេក្ខជនគណបក្ស ខ មានមធ្យមភាគ ៧៥៩,០០ ធំជាងគេ

អទ២ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជនគណបក្សនីមួយៗទទួលបានក្នុងការបែងចែក លើកទី២ គឺបញ្ជីបេក្ខជនគណបក្សនយោបាយ ខ ត្រូវទទួលអាសនៈ

**មធ២ អទ៣ មធ៣ អទ៤ មធ៤ អទ៥ មធ៥ អទ៦** តាងឱ្យតាមលំដាប់លំដោយនៃការគណនាមធ្យមភាគខ្ពស់បំផុត និងអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលតាមរូបមន្តមធ្យមភាគខ្ពស់បំផុតនៃជំហានទី៣ ដដែល។

លទ្ធផលនៃការបែងចែកអាសនៈក្នុងមណ្ឌលបោះឆ្នោតឃុំ B គឺ៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ: ១
- បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ: ១
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ: ១
- បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ: ១
- បញ្ជីបេក្ខជននៃគណបក្ស **ឆ** បានទទួលអាសនៈ: ១
- បញ្ជីបេក្ខជននៃគណបក្ស **គ** និង **ច** ពុំទទួលបានអាសនៈទេ
- សរុបអាសនៈទាំងអស់ = ៥អាសនៈ។

### គ. ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ឬច្រើនបោះបង់ចោលអាសនៈ ឬត្រូវបានលុបចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយ

ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនបានទទួល ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជនទាំងអស់នោះលែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀត។ គធ.ឃប ត្រូវបែងចែកអាសនៈដែលនៅទំនេរឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀត ដែលបានចូលរួមបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធក្នុងអំឡុងពេលយ៉ាងយូរ ១៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានលិខិតបោះបង់ចោលជាផ្លូវការពីគណបក្សនយោបាយ ឬប្រកាសលុបឈ្មោះគណបក្សនយោបាយពីបញ្ជីគណបក្សនយោបាយ ឬប្រកាសរំលាយគណបក្សនយោបាយ។ គណបក្សនយោបាយអាចប្រកាសមិនទទួលយកអាសនៈដោយត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ឃប ក្នុងអំឡុងពេលយ៉ាងយូរ ៥ថ្ងៃ តាមការកំណត់របស់ គធ.ឃប។ នៅមុនការបែងចែកអាសនៈដែលនៅទំនេរ គធ.ឃប ត្រូវធ្វើលិខិតជាផ្លូវការទៅគណបក្សនយោបាយផ្សេងៗទៀតដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។ ការបែងចែកអាសនៈដែលនៅទំនេរត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

- **ជំហានទី១** ការកំណត់កូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបាន ១អាសនៈ

ការកំណត់ចំនួនកូតា ដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើស កបឃ.ស ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ មកចែកជាមួយនឹងចំនួនអាសនៈដែលនៅទំនេរនោះ។

រូបមន្ត

$$\text{ក'}_{\text{ត}} = \frac{\text{ស'}_{\text{ស}}}{\text{អ'}_{\text{ប}}}$$

ក្នុងនោះ៖

- $\text{ក'}_{\text{ត}}$ តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក
- $\text{ស'}_{\text{ស}}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើស កបឃ.ស ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ
